ICNL

www.icnl.org
info@icnl.org

## អត្ថបទវិភាគគតិយុត្តៈ ប្រទេសកម្ពុជា

# សេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន ឆ្នាំ២០២២

## សេចក្តីផ្តើម

រាជរដ្ឋាភិបាលកម្ពុជា បាន និងកំពុងពិភាក្សាលើការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មាន អស់រយៈពេលជាច្រើនឆ្នាំមកហើយ។ កាលពីខែសីហា ឆ្នាំ២០២២ មជ្ឈមណ្ឌល ICNL បានទទួលកំណែសេចក្តីព្រាងច្បាប់ស្តីពីបទល្មើសបច្ចេកវិទ្យាព័ត៌មានជាភាសាអង់គ្លេស (សេចក្តីព្រាងច្បាប់)។[1] សេចក្តីព្រាងច្បាប់កំណែចុងក្រោយ ចុះថ្ងៃទី ២៩ ខែមិថុនា ឆ្នាំ២០២១ នេះ គឺជាកំណែលើកទី ៤ ហើយ។ ទោះបីជាកំណែសេចក្តីព្រាងច្បាប់លើកទី ៤ នេះ មានការកែប្រែល្អប្រសើរបានខ្លះបើប្រៀបនឹងកំណែសេចក្តីព្រាងច្បាប់លើកទី ៣ ក៏ដោយ[2] ក៏តែនៅមានការព្រួយបារម្ភមួយចំនួនថាសេចក្តីព្រាងច្បាប់នេះរឹតត្បិតសេរីភាពក្នុងការបញ្ចេញមតិ និងរំលោភបំពានសិទ្ធិឯកជនភាពរបស់ប្រជាជនខ្មែរ។

អត្ថបទវិភាគនេះ ធ្វើការប្រៀបធៀបសេចក្តីព្រាងច្បាប់នេះ ជាមួយនឹងច្បាប់អន្តរជាតិ ស្តង់ដារ និងការអនុវត្តល្អៗ ពាក់ព័ន្ធនឹងសេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិឯកជនភាព។ សេចក្តីព្រាងច្បាប់នេះ មិនបានចែងពីបញ្ហាទាំងអស់នេះទេ។

នៅក្នុងសេចក្តីព្រាងច្បាប់នេះ មានមាត្រាមួយចំនួនសំដៅរឹតត្បិតដោយមិនសមហេតុផលទៅលើសេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិឯកជនភាព។ ទោះបីជាមានកែប្រែពាក់ព័ន្ធនឹងសេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិឯកជនភាព ដោយអនុលោមតាមកាតព្វកិច្ចផ្លូវច្បាប់ជាអន្តរជាតិរបស់ប្រទេសកម្ពុជាក៏ដោយ សេចក្តីព្រាងច្បាប់នេះនៅតែអនុញ្ញាតឱ្យរាជរដ្ឋាភិបាលកម្ពុជាអាចបង្ការទប់ស្កាត់ ស៊ើបអង្កេត និងផ្តន្ទាទោសសកម្មភាពឧក្រិដ្ឋណាដែលកើតមានឡើងតាមប្រព័ន្ធកុំព្យូទ័របាន។

[1] សេចក្តីព្រាងច្បាប់បកប្រែជាភាសាអង់គ្លេសនេះ មានដាក់សម្គាល់ថាជាការបកប្រែផ្លូវការរបស់នាយកដ្ឋានប្រឆាំងបទល្មើសបច្ចេកវិទ្យា។

[2] សូមមើល អត្ថបទវិភាគគតិយុត្តៈ សេចក្តីព្រាងច្បាប់ស្តីពីឧក្រិដ្ឋកម្មបច្ចេកវិទ្យា (ខែធ្នូ ឆ្នាំ២០២០) របស់មជ្ឈមណ្ឌល ICNL

INTERNATIONAL CENTER
FOR NOT-FOR-PROFIT LAW

1126 16th Street NW #400
Washington, DC 20036

មជ្ឈមណ្ឌល ICNL មានការព្រួយបារម្ភ ថាសេចក្តីព្រាងច្បាប់នេះអាចរឹតត្បិតដោយមិនសមហេតុផលទៅលើសេរីភាពក្នុងការបញ្ចេញមតិ ឬសិទ្ធិឯកជនភាព លើចំណុច ៤ សំខាន់ៗដូចខាងក្រោមនេះ៖

- **ការរឹតត្បិតមិនច្បាស់លាស់ទៅលើចំណាត់ថ្នាក់ជាក់លាក់នៃការបញ្ចេញមតិដែលកម្រិតសេរីភាពក្នុងការបញ្ចេញមតិ៖** សេចក្តីព្រាងច្បាប់ កំណត់ប្រភេទនៃការបញ្ចេញមតិមួយចំនួនថាជាបទឧក្រិដ្ឋ ដោយផ្អែកលើការប្រើភាសាមិនច្បាស់លាស់ដែលអាចនាំឱ្យមានការរឹតត្បិតមិនស្របច្បាប់ទៅលើសេរីភាពក្នុងការបញ្ចេញមតិ។
- **កាតព្វកិច្ចមិនសមហេតុផលរបស់ «អ្នកផ្តល់សេវា»៖** សេចក្តីព្រាងច្បាប់ តម្រូវឱ្យអ្នកផ្តល់សេវា គ្រប់គ្រង «ព័ត៌មានរបស់អ្នកប្រើប្រាស់» ហើយត្រូវប្រគល់ព័ត៌មានទាំងនោះទៅឱ្យអាជ្ញាធររដ្ឋាភិបាល។ អាស្រ័យតាមការបកស្រាយសេចក្តីព្រាងច្បាប់ លក្ខខណ្ឌតម្រូវទាំងនេះអាចធ្វើឱ្យមានការពិបាកក្នុងការប្រើប្រាស់អ៊ិនធើណិតបែបអនាមិក និងរារាំងការប្រើប្រាស់កូដនីយកម្ម (encryption) និងមុខងារសុវត្ថិភាពផ្សេងៗទៀត។
- **ការត្រួតពិនិត្យតាមផ្លូវតុលាការ ឬការកំណត់ពេលវេលានៅមានកម្រិតសម្រាប់ការធ្វើសកម្មភាពតាមដាន៖** សេចក្តីព្រាងច្បាប់បានផ្តល់សិទ្ធិអំណាចយ៉ាងធំធេងដល់អាជ្ញាធររដ្ឋាភិបាលក្នុងការតាមដានការទំនាក់ទំនងតាមអេឡិចត្រូនិច ប៉ុន្តែជាញឹកញាប់ សេចក្តីព្រាងច្បាប់នេះមិនតម្រូវឱ្យមានការឯកភាពតាមផ្លូវតុលាការ មុនពេលចាប់ផ្តើមសកម្មភាពតាមដាននោះទេ ព្រមទាំងមិនបានកំណត់ពេលវេលាជាក់លាក់ណាមួយសម្រាប់ធ្វើសកម្មភាពតាមដាននោះដែរ។ ជាផលវិបាក ការតាមដានតាមប្រព័ន្ធអេឡិចត្រូនិចអាចផ្តួចផ្តើមបានតាមចិត្ត និងអាចចំណាយពេលរាប់ឆ្នាំ ដែលអាចរំលោភបំពាននឹងសិទ្ធិឯកជនភាព និងសេរីភាពក្នុងការបញ្ចេញមតិ។
- **ទណ្ឌកម្មរដ្ឋបាល និងការផាកពិន័យអន្តរការណ៍ អាចត្រូវបានប្រើប្រាស់សំដៅអង្គការសង្គមស៊ីវិល៖** ក្រសួងមហាផ្ទៃ មានសិទ្ធិអំណាចក្នុងការដាក់ទណ្ឌកម្មរដ្ឋបាល ដូចជាការព្យួរ ឬការដកហូតអាជ្ញាប័ណ្ណជាដើម។ ក្រសួងមហាផ្ទៃ ក៏មានសិទ្ធិអំណាចប្រហាក់ប្រហែលគ្នាក្នុងការផាកពិន័យអ្នកបំពានច្បាប់ផងដែរ ប៉ុន្តែចំនួនទឹកប្រាក់ផាកពិន័យមិនទាន់បានកំណត់នៅឡើយទេ ហើយសេចក្តីព្រាងច្បាប់នេះមិនមានចែងពីលក្ខណៈវិនិច្ឆ័យនៃពេលវេលាសមស្របសម្រាប់ឱ្យក្រសួងមហាផ្ទៃដាក់ទណ្ឌកម្មរដ្ឋបាល ឬការពិន័យអន្តរការណ៍នោះទេ។

## ច្បាប់អន្តរជាតិ

មាត្រា ១៩ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ (កតិកាសញ្ញា ICCPR) តម្រូវឱ្យរដ្ឋសមាជិកធានាពីសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ រួមទាំងសិទ្ធិទទួលបាន និងចែករំលែកព័ត៌មាន និងគំនិតគ្រប់រូបភាព ដោយគ្មានដែនកំណត់។[3] គណៈកម្មាធិការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ បានថ្លែងថា «រាល់ការរឹតត្បិតទៅលើប្រតិបត្តិការគេហទំព័រ ប្លុក (Blog) ឬប្រព័ន្ធអេឡិចត្រូនិចផ្សេងៗនៅលើប្រព័ន្ធអ៊ិនធើណិត ឬប្រព័ន្ធចែកចាយព័ត៌មានផ្សេងទៀត» ត្រូវតែអនុលោមតាមមាត្រា ១៩ នៃកតិកាសញ្ញា ICCPR ។[4]

ការរឹតត្បិតសេរីភាពក្នុងការបញ្ចេញមតិដែលត្រូវបានធានានៅក្នុងមាត្រា ១៩ នៃកតិកាសញ្ញា ICCPR គឺជាការស្របច្បាប់ ក៏ប៉ុន្តែ ទាល់តែការរឹតត្បិតនោះត្រូវឆ្លងផុតការធ្វើតេស្តត្រួតគ្នាបីចំណុចជាមុនសិន។[5] ដោយយោងតាមការធ្វើតេស្ត៖

(1) ការរឹតត្បិតនេះ ត្រូវតែកំណត់ដោយច្បាប់ ដែលមានលក្ខណៈច្បាស់លាស់ និងអាចរកមើលបានសម្រាប់មនុស្សគ្រប់រូប(ដូចជា ការប្រកាន់ខ្ជាប់ទៅនឹងគោលការណ៍ប្រមើទុកមុន និងតម្លាភាព)

(2) ការរឹតត្បិតត្រូវតែមានគោលបំណងមួយ ដូចមានចែងនៅក្នុងកថាខណ្ឌទី ៣ នៃមាត្រា ១៩ នៃកតិកាសញ្ញា ICCPR ដូចជា៖ (i) ការពារសិទ្ធិ ឬកិត្តិសព្ទរបស់អ្នកដទៃ (ii) ការពារសន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ ឬសុខមាលភាព ឬសីលធម៌សាធារណៈ (គោលការណ៍នីត្យានុកូលភាព) និង

(3) ការរឹតត្បិតត្រូវតែបង្ហាញថាចាំបាច់ និងជាមធ្យោបាយរឹតត្បិតតិចតួចបំផុត ដើម្បីសម្រេចបាននូវគោលដៅដែលលើកឡើង (ដូចជា ការប្រកាន់ខ្ជាប់ទៅនឹងគោលការណ៍ចាំបាច់ និងសមាមាត្រ)

---

[3] ព្រះរាជាណាចក្រកម្ពុជាក្លាយជារដ្ឋសមាជិកនៃកតិកាសញ្ញា ICCPR នៅថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩២

[4] កថាខណ្ឌទី ៤៣ នៃសេចក្តីពន្យល់ទូទៅលេខ ៣៤ របស់គណៈកម្មាធិការសិទ្ធិមនុស្ស ៖ មាត្រា ១៩៖ សេរីភាពក្នុងការបញ្ចេញមតិ និងគំនិត។ ឯកសាររបស់អង្គការសហប្រជាជាតិ #CCPR/C/GC/34 (ឆ្នាំ ២០១១)

[5] *សូមមើល* កថាខណ្ឌទី ៦៩ នៃ«របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ ដោយលោក Frank La Rue» ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០១១។ ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/HRC/17/27

ដូចគ្នានេះដែរ សិទ្ធិឯកជនភាព មានចែងនៅក្នុងមាត្រា ១៧ នៃកតិកាសញ្ញា ICCPR «១. គ្មានជនណាម្នាក់ ត្រូវទទួលរងការជ្រៀតជ្រែកតាមអំពើចិត្ត ឬដោយខុសច្បាប់ ក្នុងជីវិតឯកជន គ្រួសារ លំនៅដ្ឋាន សំបុត្រឆ្លើយឆ្លងរបស់ខ្លួន ឬត្រូវរងការប៉ះពាល់ ដោយខុសច្បាប់ទៅលើកិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ខ្លួនឡើយ។ ២. ជនគ្រប់រូបមាន សិទ្ធិឱ្យច្បាប់ការពារប្រឆាំងនឹងការជ្រៀតជ្រែក ឬការប៉ះពាល់បែបនេះ។» សិទ្ធិឯកជនភាព ផ្អែកទៅលើបរិវេណជាមូលដ្ឋាន ដែលបុគ្គលមាន «ដែនឯកជន» ដែលពួកគាត់អាចទាក់ទងគ្នាបានដោយសេរី ដោយគ្មានការជ្រៀតជ្រែកពីរដ្ឋ។[6] «ដើម្បីអាចឱ្យបុគ្គលអនុវត្តសិទ្ធិឯកជនភាពរបស់ខ្លួនបានក្នុងទំនាក់ទំនង ពួកគេត្រូវតែធានាថាទំនាក់ទំនងទាំងនោះ មានឯកជនភាពរហូត ត្រូវបានធានា និងអនាមិកបាន ប្រសិនបើពួកគេជ្រើសរើសបែបនោះ»។[7]

ទោះបីជាមាត្រា ១៧ កតិកាសញ្ញា ICCPR ប្រមើមើលពីភាពចាំបាច់ ភាពស្របច្បាប់ និងការរឹតត្បិតសមាមាត្រពាក់ព័ន្ធនឹងសិទ្ធិឯកជនភាពក្តី អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ «អ្នករាយការណ៍ពិសេស» លើកឡើងថាសិទ្ធិឯកជនភាព គួរតែជាកម្មវត្ថុនៃការធ្វើតេស្តពីកម្រិតអាចអនុញ្ញាតបានដូចនឹងសិទ្ធិសេរីភាពធ្វើដំណើរដែរ ដោយបានស្រាយបំភ្លឺនៅក្នុងសេចក្តីពន្យល់ទូទៅរបស់គណៈកម្មាធិការសិទ្ធិមនុស្សលេខ ២៧ ក្នុងកថាខណ្ឌ ១៥ ថា៖

- (ក) ការរឹតត្បិតត្រូវតែមានកំណត់ដោយច្បាប់
- (ខ) លក្ខខណ្ឌសំខាន់បំផុតនៃសិទ្ធិមនុស្ស មិនមែនជាកម្មវត្ថុនៃការរឹតត្បិត
- (គ) ការរឹតត្បិតត្រូវតែចាំបាច់នៅក្នុងសង្គមប្រជាធិបតេយ្យ
- (ឃ) នៅពេលអនុវត្តការរឹតត្បិត ឆន្ទានុសិទ្ធិមិនត្រូវប្រើដោយផ្តេសផ្តាសនោះទេ
- (ង) ចំពោះការរឹតត្បិតដែលអាចអនុញ្ញាតឱ្យធ្វើបាន វាមិនគ្រប់គ្រាន់ទេប្រសិនបើសំដៅសម្រេចតាមគោលដៅស្របច្បាប់តែមួយនោះ។ ការរឹតត្បិតនោះត្រូវតែចាំបាច់ដើម្បីឈានទៅដល់គោលដៅស្របច្បាប់។ និង

[6] សូមមើល កថាខណ្ឌទី ៤. ៨២ នៃឯកសារ «ច្បាប់សិទ្ធិមនុស្ស និងការអនុវត្ត» រៀបរៀងដោយ Lord Lester និង D. Pannick (eds.) (Butterworth ឆ្នាំ២០០៤)

[7] កថាខណ្ឌទី ២៣ នៃ «របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ ដោយលោក Frank La Rue» ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០១៣ ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/HRC/23/40។

(ច) វិធានការតឹងរឹង ត្រូវតែអនុលោមតាមគោលការណ៍សមាមាត្រ សមស្របដើម្បីសម្រេចបានមុខងារការពារ ជាលិខិតុបករណ៍បំពានតិចតួចបំផុតក្នុងចំណោមលិខិតុបករណ៍ដែលអាចសម្រេចតាមលទ្ធផលចង់បាន និងត្រូវសមាមាត្រទៅនឹងផលប្រយោជន៍ដែលទទួលបានការការពារ។[8]

សេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិឯកជនភាព មានទំនាក់ទំនងគ្នាទៅវិញទៅមក៖ «សិទ្ធិឯកជនភាព តែងតែត្រូវបានយល់ថាជាលក្ខខណ្ឌតម្រូវសំខាន់មួយសម្រាប់ការទទួលបានសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។»[9] ការដាក់កម្រិត ឬការរឹតត្បិតទៅលើសិទ្ធិទាំងនេះណាមួយ ផ្តល់ផលប៉ះពាល់ដល់ការអាស្រ័យផលនៃសិទ្ធិមួយទៀត។ គ្រាន់តែការរឹតត្បិតលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ត្រូវឆ្លងកាត់ការធ្វើតេស្តត្រួតគ្នាលើបីចំណុច ដែលដកស្រង់ចេញពីមាត្រា ១៩ នៃកតិកាសញ្ញា ICCPR ដើម្បីអាចទទួលបានភាពស្របច្បាប់បាន ហើយការរឹតត្បិតលើសិទ្ធិឯកជនភាព អាចស្របច្បាប់បាន លុះត្រាតែសិទ្ធិនេះឆ្លងកាត់ការធ្វើតេស្តដែលមានចែងនៅក្នុងសេចក្តីពន្យល់ទូទៅលេខ 27.15។[10]

## ការវិភាគ

### ការប្រើភាសាមិនច្បាស់លាស់ធ្វើឱ្យអន្តរាយដល់សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ

**បញ្ហា៖** ជំពូកទី ៧ នៃសេចក្តីព្រាងច្បាប់ កំណត់អំពើមួយចំនួនថាជាបទល្មើសបច្ចេកវិទ្យាព័ត៌មាន។ ជាការសំខាន់ដែលអាជ្ញាធរមានលទ្ធភាពក្នុងការបង្ការ ស៊ើបអង្កេត និងអាចផ្តន្ទាទោសបទល្មើសបច្ចេកវិទ្យាព័ត៌មានបានដោយស្របច្បាប់ ក៏ប៉ុន្តែបទល្មើសមួយចំនួនដែលចែងនៅក្នុងជំពូក

---

[8] កថាខណ្ឌទី ១៥ នៃសេចក្តីពន្យល់ទូទៅលេខ ២៧ របស់គណៈកម្មាធិការសិទ្ធិមនុស្ស៖ សេរីភាពធ្វើដំណើរ (មាត្រា ១២) ឯកសាររបស់អង្គការសហប្រជាជាតិ #CCPR/C/21/Rev.1/Add.9 (ឆ្នាំ ១៩៩៩); កថាខណ្ឌទី ២៩ នៃ "របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ ដោយលោក Frank La Rue" ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០១៣ ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/HRC/23/40។

[9] កថាខណ្ឌទី ២៤ នៃ «របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ ដោយលោក Frank La Rue» ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០១៣ ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/HRC/23/40

[10] កថាខណ្ឌទី ២៩ នៃ «របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ ដោយលោក Frank La Rue» ចុះថ្ងៃទី ១៧ ខែមេសា ឆ្នាំ២០១៣ ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/HRC/23/40

ទី៧ មានលក្ខណៈមិនច្បាស់លាស់ និងទូលំទូលាយខ្លាំង ដែលអាចបណ្តាលឱ្យមានការរឹតត្បិត ដែលមិនអាចទទួលយកបានទៅលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។

**ការវិភាគ៖** ការរឹតត្បិតទៅលើការនិយាយស្តី និងការបញ្ចេញមតិ ដែលត្រូវបានធានានៅក្នុងមាត្រា ១៩ នៃកតិកាសញ្ញា ICCPR គឺជារឿងស្របច្បាប់ លុះត្រាតែការរឹតត្បិតនោះបានឆ្លងកាត់ការធ្វើតេស្តត្រួតគ្នា ចំនួន ៣ ចំណុចនៃមាត្រា ១៩ តែប៉ុណ្ណោះ។[11]

## *មាត្រា ៤៥ នៃសេចក្តីព្រាងច្បាប់*

មាត្រា ៤៥ នៃសេចក្តីព្រាងច្បាប់ កំណត់អំពើ «ការផ្តល់ព័ត៌មានមិនពិត» និង «សេចក្តីថ្លែងក្លែង» ដែលធ្វើឡើងនៅលើប្រព័ន្ធកុំព្យូទ័រ ឬឧបករណ៍ទូរគមនាគមន៍ ជាបទឧក្រិដ្ឋ ដោយចែងថា៖

> ១. ជនណាដែលផ្សព្វផ្សាយ ឬចែកចាយព័ត៌មានក្លែងតាមមធ្យោបាយបច្ចេកវិទ្យាព័ត៌មាន បង្កឱ្យមានអន្តរាយដោយចេតនាដល់ទំនាក់ទំនងជាមួយនឹងបណ្តាប្រទេសដទៃ សន្តិសុខសង្គម និងសណ្តាប់ធ្នាប់សាធារណៈ សេដ្ឋកិច្ច ឬបង្កឱ្យមានការប្រកាន់ជាតិសាសន៍ ឬប៉ះពាល់ដល់វប្បធម៌ប្រពៃណី ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ខែ ទៅ ៣ ឆ្នាំ និងពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល។
>
> ២. ជនណាដែលផ្សព្វផ្សាយ ឬចែកចាយព័ត៌មានក្លែងតាមមធ្យោបាយបច្ចេកវិទ្យាព័ត៌មាន បង្កឱ្យមានអន្តរាយដោយចេតនាដល់ការការពារជាតិ ឬសន្តិសុខជាតិ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ ឆ្នាំ ទៅ ៥ ឆ្នាំ និងពិន័យជាប្រាក់ពី ១០ ០០០ ០០០ (ដប់លាន) រៀល ទៅ ៥០ ០០០ ០០០ (ហាសិបលាន) រៀល។[12]

បទប្បញ្ញត្តិទាំងនេះ សង្កត់ធ្ងន់ជាពិសេសទៅលើ ច្បាប់ស្តីពី «ការប្រឆាំងនឹងព័ត៌មានក្លែងក្លាយ» ដែលមិនមានភាពស៊ីសង្វាក់ជាមួយនឹងសេរីភាពក្នុងការបញ្ចេញមតិនោះទេ។[13] ជាជាងបង្ការមិន

---

11 *ជាឧទាហរណ៍ សូមមើល* កថាខណ្ឌទី ៦៩ នៃ «របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ ដោយលោក Frank La Rue» ចុះថ្ងៃទី ១៦ ខែឧសភា ឆ្នាំ២០១១ ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/HRC/17/27

12 មាត្រា ៤៥ នៃសេចក្តីព្រាងច្បាប់

13 កថាខណ្ឌទី ២(ក) នៃសេចក្តីប្រកាសរួមស្តីពី «ព័ត៌មានក្លែងក្លាយ» ការឱ្យព័ត៌មានខុស និងការឃោសនា(ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ ២០១៧) របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និង

ឱ្យការផ្សព្វផ្សាយព័ត៌មានមិនត្រឹមត្រូវ ឬព័ត៌មានមិនពិត[14] សេចក្តីព្រាងច្បាប់នេះបែរជាបំបាក់ទឹកចិត្តសង្គមស៊ីវិល និងសាធារណៈជនទាក់ទងនឹងការបញ្ចេញមតិដែលស្របច្បាប់ និងសំខាន់ៗទៅវិញ។ ការអនុញ្ញាតឱ្យរដ្ឋាភិបាលក្លាយជាអាជ្ញាកណ្តាលកាត់សេចក្តីលើការពិត ទំនងជាលុបបំបាត់ជាបណ្តើរៗនូវបទដ្ឋានប្រជាធិបតេយ្យដែលមានស្រាប់ និងមិនអាចទប់ស្កាត់ខ្លឹមសារក្លែងបានថែមទៀត។[15]

ជំនាញការអន្តរជាតិស្តីពីសេរីភាពក្នុងការបញ្ចេញមតិបានលើកឡើងយ៉ាងច្បាស់ថា ច្បាប់ស្តីពី «ការប្រឆាំងនឹងព័ត៌មានក្លែងក្លាយ» រំលោភបំពាននឹងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ។ អ្នករាយការណ៍ពិសេសអន្តរជាតិស្តីពីសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និង/ឬ សារព័ត៌មាន បានអនុម័តលើសេចក្តីប្រកាសរួមមួយកាលពីខែមីនា ឆ្នាំ២០១៧ ដែលបានកត់សម្គាល់ជាពិសេសថា «ការហាមឃាត់ជាទូទៅលើការចែកចាយព័ត៌មាន ដោយផ្អែកលើគំនិតបែបស្រពេចស្រពិល និងមានន័យមិនប្រាកដប្រជា រួមមាន «ព័ត៌មានក្លែង» ឬ «ព័ត៌មានបែបបំផ្លើស» គឺមិនមានភាពស៊ីសង្វាក់នឹងស្តង់ដារអន្តរជាតិស្តីពីការរឹតត្បិតលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិនោះទេ... ហើយត្រូវតែលុបបំបាត់ចោល។»[16] សេចក្តីប្រកាសរួមដែលធ្វើឡើងដោយអាណត្តិតំណាងទាំងនេះ ត្រូវបានចាត់

យោបល់, អ្នកតំណាងសេរីភាពសារព័ត៌មាននៃអង្គការសន្តិសុខ និងកិច្ចសហប្រតិបត្តិការនៅអឺរ៉ុប (OSCE), អ្នករាយការណ៍ពិសេសស្តីពីសេរីភាពក្នុងការបញ្ចេញមតិ នៃអង្គការបណ្តាប្រទេសនៅទ្វីបអាមេរិក (OAS) និងអ្នករាយការណ៍ពិសេសស្តីពីសេរីភាពក្នុងការបញ្ចេញមតិ និងការទទួលបានព័ត៌មាននៃគណៈកម្មការអាហ្វ្រិកទទួលបន្ទុកសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន (ACHPR)

14 ដោយយោងតាមអង្គការយូណេស្កូ «ព័ត៌មានមិនត្រឹមត្រូវ» សំដៅលើ «ព័ត៌មានក្លែងក្លាយ ដែលមិនបង្កើតឡើងក្នុងចេតនាបង្កឱ្យមានគ្រោះថ្នាក់នោះទេ» ចំណែកឯ «ព័ត៌មានមិនពិត» គឺជា «ព័ត៌មានក្លែងក្លាយ និងបង្កើតឡើងដោយមានចេតនាបង្កឱ្យមានគ្រោះថ្នាក់ដល់ជនណាម្នាក់ ក្រុមសង្គម អង្គការ ឬប្រទេស។» (ព័ត៌មានវាយប្រហារបុគ្គល គឺជាព័ត៌មានដែលផ្អែកលើការពិត ហើយត្រូវបានយកមកប្រើប្រាស់ដើម្បីបង្កគ្រោះថ្នាក់ដល់ជនណាម្នាក់ ក្រុមសង្គម អង្គការ ឬប្រទេស។)« *វិជ្ជាជីវៈសារព័ត៌មាន »ដំណឹងក្លែងក្លាយ" និងព័ត៌មានមិនពិត៖ សៀវភៅណែនាំសម្រាប់អប់រំ និងបណ្តុះបណ្តាលសារព័ត៌មាន"* អង្គការយូណេស្កូ តំណភ្ជាប់ https://en.unesco.org/fightfakenews.

15 យុទ្ធនាការអប់រំ និងអក្ខរកម្មសារព័ត៌មាន មានប្រសិទ្ធភាពល្អប្រសើរសម្រាប់ប្រយុទ្ធប្រឆាំងនឹងដំណឹងក្លែងក្លាយនៅក្នុងដែនសាធារណៈ។ សម្រាប់ព័ត៌មានបន្ថែម *ជាឧទាហរណ៍ សូមមើល របាយការណ៍ស្តីពី «របៀបប្រយុទ្ធប្រឆាំងនឹងដំណឹងក្លែងក្លាយ និងព័ត៌មានក្លែង»* រៀបរៀងដោយ Darrell M. West ផ្សព្វផ្សាយដោយ Brookings ថ្ងៃទី ១៨ ខែធ្នូ ឆ្នាំ២០១៧ អាចរកមើលបានតាមរយៈ https://www.brookings.edu/research/how-to-combat-fake-news-and-disinformation/

16 កថាខណ្ឌទី ២(ក) នៃសេចក្តីប្រកាសរួមស្តីពី "ព័ត៌មានក្លែងក្លាយ" ការឱ្យព័ត៌មានខុស និងការឃោសនា(ចុះថ្ងៃទី៣ ខែមីនា ឆ្នាំ២០១៧) របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់, អ្នកតំណាងសេរីភាពសារព័ត៌មាននៃអង្គការសន្តិសុខ និងកិច្ចសហប្រតិបត្តិការនៅអឺរ៉ុប (OSCE), អ្នករាយការណ៍ពិសេសស្តីពីសេរីភាពក្នុងការបញ្ចេញមតិ នៃអង្គការបណ្តាប្រទេសនៅទ្វីបអាមេរិក (OAS) និងអ្នករាយការណ៍ពិសេសស្តីពីសេរីភាពក្នុងការបញ្ចេញមតិ និងការទទួលបានព័ត៌មាននៃគណៈកម្មការអាហ្វ្រិកទទួលបន្ទុកសិទ្ធិមនុស្ស និងសិទ្ធិប្រជាជន (ACHPR)

ទុកថាជាការបកស្រាយដែលសមហេតុផលបំផុត និងគួរឱ្យជឿបាន ពាក់ព័ន្ធនឹងច្បាប់សិទ្ធិមនុស្សអន្តរជាតិដែលមានស្រាប់ទៅលើប្រធានបទដែលបានលើកឡើងនេះ។[17]

ប្រសិនបើមើលពីទិដ្ឋភាពគោលនយោបាយការកំណត់ថាជាបទឧក្រិដ្ឋនូវព័ត៌មាន «ក្លែង» ឬខ្លឹមសារ «ក្លែង» ដូចជានៅក្នុងមាត្រា ៤៥ នៃសេចក្តីព្រាងច្បាប់ នឹងៈ (ក) បង្ក្រាបរាល់សារព័ត៌មានឯករាជ្យ ជាពិសេសសារព័ត៌មាន និងការរាយការណ៍ព័ត៌មានទាំងឡាយណា ដែលរិះគន់គោលនយោបាយរដ្ឋាភិបាល (ខ) បង្កើតជាឥទ្ធិពលដែលប៉ះពាល់ធ្ងន់ធ្ងរទៅដល់ការពិភាក្សាជាសាធារណៈ (គ) ធ្វើឱ្យទន់ខ្សោយដល់គណនេយ្យភាពរដ្ឋាភិបាល និងសាធារណៈ ដោយហេតុថាការបញ្ចេញមតិយោបល់ រិះគន់ នឹងត្រូវផ្តន្ទាទោសទៅវិញ (ឃ) ធ្វើឱ្យមានការផ្តល់ព័ត៌មានកាន់តែតិច ស្តីពីតម្រូវការសហគមន៍សម្រាប់ផ្តល់ឱ្យអ្នកសម្រេចចិត្តរបស់រដ្ឋាភិបាល ជាហេតុនេះបង្កជាឧបសគ្គដល់លទ្ធភាពរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហានានា និង (ង) ធ្វើឱ្យចុះខ្សោយដល់លទ្ធិប្រជាធិតេយ្យ។ ប្រសិនបើនិយាយបែបចំអកឡកឡឺយ ច្បាប់ដែលព្យាយាមហាមឃាត់ការផ្សព្វផ្សាយព័ត៌មានក្លែង តាមពិតអាចនាំឱ្យមានការបង្ក្រាបដល់ «ព័ត៌មានពិត» រួមទាំងការបង្ហាញភាពមិនប្រកាន់បក្សពួក ការវិភាគបែបអព្យាក្រឹត្យ ជាពិសេសក្នុងករណីដែលការវិភាគនោះសំដៅដេញដោលទៅលើគោលនយោបាយ ឬគោលជំហររបស់រដ្ឋាភិបាល។

## ការរឹតត្បិតខ្លឹមសារដែលមានលក្ខណៈទូលំទូលាយពេក និងមិនមានភាពច្បាស់លាស់

ចំណាត់ប្រភេទនៃការនិយាយស្តីដែលហាមឃាត់នៅក្នុងមាត្រា ៤៥ នៃសេចក្តីព្រាងច្បាប់ មានលក្ខណៈទូលាយពេក និងមិនច្បាស់លាស់សោះក្នុងការបំពេញតាមគោលការណ៍នៃភាពអាចសន្មតបាន និងតម្លាភាព។ គោលការណ៍ទាំងនេះ ដែលបង្កើតបានជាលក្ខខណ្ឌតម្រូវ «កំណត់ដោយច្បាប់» តាមមាត្រា ១៩ នៃកតិកាសញ្ញា ICCPR ស្តីពីការធ្វើតេស្តសាកល្បងទាំងបីចំណុច មិនត្រូវបានបំពេញតាមទាល់តែសោះ ដោយហេតុថាច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តិ ត្រូវបានអនុម័តជាផ្លូវការនោះទេ។ ដើម្បីបំពេញតាមលក្ខខណ្ឌតម្រូវទាំងនេះ ការរឹតត្បិតទៅលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ត្រូវតែអាចសន្មតទុកជាមុនបាន និងមានតម្លាភាព ហើយច្បាប់ដែលកំពុងលើកឡើងនេះ ត្រូវតែតាក់តែងឡើងដោយមានភាពច្បាស់លាស់គ្រប់គ្រាន់ដែលអាចឱ្យបុគ្គល និង

---

[17] *សូមមើល* ទំព័រ ២៥១-២៥៧ នៃឯកសាររបស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ "ការអភិវឌ្ឍជាបណ្តើរៗនៃស្តង់ដារអន្តរជាតិទាក់ទងនឹងសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ" របស់ Toby Mendel នៅក្នុង T. McGonaple និង Y. Donders (eds.), អង្គការសហប្រជាជាតិ និងសេរីភាពក្នុងការបញ្ចេញមតិ និងព័ត៌មានៈ ទិដ្ឋភាពគួរឱ្យបារម្ភ, បោះពុម្ពផ្សាយដោយសារព័ត៌មានរបស់សកលវិទ្យាល័យ Cambridge (ឆ្នាំ២០១៥)

ជនត្រូវផ្តន្ទាទោសអនុលោមតាមច្បាប់បាន។[18] ចំណាត់ប្រភេទនៃខ្លឹមសារដែលត្រូវបានហាមឃាត់ក្រោមមាត្រា ៤៥ នៃសេចក្តីព្រាងច្បាប់ មានលក្ខណៈមិនច្បាស់លាស់ ដែលមិនអាចបំពេញតាមគោលការណ៍នៃភាពអាចសន្មតទុកជាមុនបាន និងតម្លាភាព ដោយហេតុថាចំណាត់ប្រភេទនេះមានលក្ខណៈទូលាយពេកសម្រាប់ឱ្យបុគ្គលដឹងថាខ្លឹមសារបែបណាដែលអាចអនុញ្ញាត ឬមិនអនុញ្ញាតឱ្យបង្កើតបាន។

- *បង្កឱ្យមានភាពអន្តរាយដល់ទំនាក់ទំនងជាមួយនឹងប្រទេសដ៏ទៃ សន្តិសុខសង្គម និងសណ្តាប់ធ្នាប់សាធារណៈ សង្គម សេដ្ឋកិច្ច៖*

  ចំណាត់ប្រភេទនៃការនិយាយស្តីនេះ មានលក្ខណៈទូលំទូលាយណាស់សម្រាប់ឱ្យបុគ្គលដឹងថាអ្វីដែលគាត់អាចនិយាយ ឬមិនអាចនិយាយបាន ហេតុដូច្នេះការហាមឃាត់នេះមិនបំពេញតាមចំណុចទី១ នៃការធ្វើតេស្តចំណុចទាំងបីចំណុច ស្របតាមមាត្រា ១៩ នៃកតិកាសញ្ញា ICCPR នោះទេ។ ការរិះគន់ពីទំនាក់ទំនងការបរទេសរបស់កម្ពុជាស្ទើរតែទាំងអស់ គោលនយោបាយអន្តោប្រវេសន៍ ឬការអនុវត្តតាមទំនៀមទំលាប់ អាចត្រូវបានមើលឃើញថាជាការបង្កអន្តរាយដល់ទំនាក់ទំនងរបស់ប្រទេសកម្ពុជាជាមួយនឹងបណ្តាប្រទេសផ្សេងទៀត។

  ដូចគ្នានេះដែរ ការហាមឃាត់ទៅលើការធ្វើសេចក្តីថ្លែង «ក្លែង» ដែលអាច «បង្កអន្តរាយដល់សន្តិសុខសង្គម» ឬ «បង្កអន្តរាយដល់សង្គម» គឺមានលក្ខណៈទូលំទូលាយ និងមិនអាចកំណត់បាន ដែលធ្វើឱ្យសាធារណជនពិបាកដឹងជាមុនថាអំពើអ្វី ឬការនិយាយស្តីបែបណាដែលអាចអនុញ្ញាតបាន និងការនិយាយស្តីអ្វីដែលខុសច្បាប់។ ជាឧទាហរណ៍ វិសាលភាពព័ត៌មាន ពាក់ព័ន្ធនឹងបាតុកម្ម ឬការប្រឆាំងតវ៉ា ឬការលើកឡើងពីការរំលោភបំពានសិទ្ធិមនុស្សអាចត្រូវបានចាត់ទុកថាជាការបង្កអន្តរាយដល់សណ្តាប់ធ្នាប់សាធារណៈ ឬសង្គម។

  ជាចុងក្រោយ ការនិយាយស្តីដែល «ប៉ះពាល់ដល់សេដ្ឋកិច្ច» អាចរួមបញ្ចូលវិសាលភាពព័ត៌មានពាក់ព័ន្ធនឹងអំពើពុករលួយ ពន្ធដារ ឬគម្រោងអភិវឌ្ឍន៍នានា។ តើរបាយការណ៍

[18] កថាខណ្ឌទី ១២ នៃ «របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ ដោយ Davide Kaye» ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៦ ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/71/373 (“ចំណុចទី ១ នៃការធ្វើតេស្តបីចំណុចតម្រូវឱ្យការរឹតត្បិតទៅលើសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ ត្រូវតែអាចសន្មតបានមុន និងមានតម្លាភាព ការរឹតត្បិត «ត្រូវតែតាក់តែងឡើងដោយមានភាពច្បាស់លាស់គ្រប់គ្រាន់ដើម្បីអាចឱ្យទាំងបុគ្គល និងអ្នកដែលរងការចោទប្រកាន់ពីការប្រព្រឹត្តនោះក្នុងការកំណត់ពីការប្រព្រឹត្តិ....»)។

មួយចេញពីធនាគារពិភពលោក ដែលទាយទុកជាមុនពីអត្រាកំណើនផលិតផលក្នុងស្រុកសរុប (GDP) មានកម្រិតទាបជាងអត្រាចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ អាចក្លាយជាការប្រព្រឹត្តខុសនឹងច្បាប់ ក្រោមការហាមឃាត់នេះទេ?

- *បង្កឱ្យមានការប្រកាន់ជាតិសាសន៍*
  បទប្បញ្ញត្តិនេះ សំដៅលើការហាមឃាត់ «ពាក្យសម្ដីស្អប់ខ្ពើម»។ ខណៈដែលរដ្ឋសមាជិកនៃអង្គការសហប្រជាជាតិ តម្រូវឱ្យហាមឃាត់ប្រើពាក្យសម្ដីស្អប់ខ្ពើម ក្រោមមាត្រា ២០(២) នៃកតិកាសញ្ញា ICCPR និងមាត្រា ៤ នៃអនុសញ្ញាអន្តរជាតិស្ដីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (អនុសញ្ញា ICERD) រាល់ការរឹតត្បិតលើពាក្យសម្ដីដែលធ្វើឡើងក្រោមមាត្រា ២០(២)នៃកតិកាសញ្ញា ICCPR ឬមាត្រា ៤ នៃអនុសញ្ញា ICERD ត្រូវតែអនុលោមតាមការធ្វើតេស្តទាំងបីចំណុច ស្របតាមមាត្រា ១៩ នៃកតិកាសញ្ញា ICCPR ។[19] ច្បាប់ដែលហាមឃាត់ពាក្យសម្ដីស្អប់ខ្ពើម ត្រូវតែរៀបចំឡើងដោយប្រុងប្រយ័ត្ន ដើម្បីធានាថាច្បាប់ទាំងនោះមិនរឹតត្បិតការបញ្ចេញមតិត្រឹមត្រូវតាមច្បាប់ដោយខ្ជីខ្ជានោះទេ។ «មាត្រា ២០ នៃកតិកាសញ្ញា ICCPR តម្រូវឱ្យមានកម្រិតចាប់ផ្ដើមខ្ពស់ ដោយសារតែ ការកម្រិតលើការនិយាយស្ដីនៅតែជាករណីពិសេសពាក់ព័ន្ធនឹងបញ្ហាគោលការណ៍គ្រឹះជាមូលដ្ឋាន។»[20] «ការតស៊ូមតិស្ដីពីការស្អប់ខ្ពើម ដោយមូលហេតុជាតិសាសន៍ ពូជសាសន៍ ឬសាសនា មិនមែនជាបទល្មើសនោះទេ។ ការតស៊ូមតិបែបនេះក្លាយជាបទល្មើសបាន លុះត្រាតែបង្កជាការញុះញង់ឱ្យរើសអើង ការប្រទូស្តរាយ ឬអំពើហិង្សា ឬនៅពេលអ្នកនិយាយព្យាយាមបង្កើតជាប្រតិកម្មពីទស្សនិកជន។»[21]

---

19 *សូមមើល* ជាឧទាហរណ៍ កថាខណ្ឌទី ៤១ នៃ «របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្ដីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ ដោយ Frank La Rue» ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១២ ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/67/357

20 កថាខណ្ឌទី ១៨ នៃ របាយការណ៍ប្រចាំឆ្នាំរបស់ឧត្តមស្នងការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ៖ របាយការណ៍បន្ថែមរបស់ឧត្តមស្នងការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ ទៅលើសិក្ខាសាលាជំនាញស្ដីពីការហាមឃាត់ការញុះញង់ឱ្យមានការស្អប់ជាតិសាសន៍ ពូជសាសន៍ ឬសាសនា, A/HRC/22/17/Add.4 ឧបសម្ព័ន្ធ, Rabit Plan of Action (ខែមករា ឆ្នាំ២០១៣)

21 កថាខណ្ឌទី ៤៣ នៃ «របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្ដីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ ដោយ Frank La Rue» ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១២ ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/67/357

អាស្រ័យហេតុនេះ ដើម្បីសម្រេចបានតាមកម្រិតចាប់ផ្តើមខ្ពស់ និងធានាបាននូវអនុលោមភាពតាមសេរីភាពក្នុងការការពារការបញ្ចេញមតិ បទប្បញ្ញត្តិច្បាប់ដែលហាមឃាត់ពាក្យសម្តីស្អប់ខ្ពើម ត្រូវតែមានធាតុផ្សំទាំងបី៖ (១) ចែងពីការតស៊ូមតិស្តីពីការស្អប់ខ្ពើម ដោយសំអាងមូលហេតុជាតិសាសន៍ ពូជសាសន៍ ឬសាសនា (២) ការតស៊ូមតិស្តីពីការស្អប់ខ្ពើមមានពាក់ព័ន្ធនឹងការញុះញង់ឱ្យមានការរើសអើង ការប្រទូស្តរាយ ឬអំពើហិង្សា និង (៣) ការញុះញង់ទាំងនោះបណ្តាលឱ្យមានការរើសអើង ការប្រទូស្តរាយ ឬអំពើហិង្សា។[22] ការរឹតត្បិតលើពាក្យសម្តីស្អប់ខ្ពើម នឹងអនុលោមតាមមាត្រា ១៩ នៃកតិកាសញ្ញា ICCPR លុះត្រាតែការរឹតត្បិតនោះមានរួមបញ្ចូលនូវចេតនាសមស្រប ការញុះញង់ជាក់ស្តែង និងកើតចេញជាលទ្ធផលដែលហាមឃាត់នោះ។ បើគ្រាន់តែដាក់ថា ហាមឃាត់រាល់ពាក្យសម្តីណាដែល «បង្កឱ្យមានការរើសអើងពូជសាសន៍» មិនបំពេញតាមធាតុផ្សំណាមួយនៃធាតុផ្សំទាំងបី ខាងលើដែលតម្រូវសម្រាប់ការហាមឃាត់ត្រឹមត្រូវទៅលើពាក្យសម្តីស្អប់ខ្ពើមនោះទេ។

បទប្បញ្ញត្តិនេះ អាចរឹតត្បិតយ៉ាងខ្លាំងទៅលើការបញ្ចេញមតិ ហើយមិនអនុលោមតាមមាត្រា ១៩ នៃកតិកាសញ្ញា ICCPR នោះទេ។

- *ប៉ះពាល់ដល់វប្បធម៌ប្រពៃណី*
  ចំណាត់ប្រភេទនៃពាក្យសម្តីនេះ មានភាពមិនច្បាស់លាស់ខ្លាំងក្នុងការស៊ីសង្វាក់ទៅនឹងច្បាប់អន្តរជាតិ។ វាក្យស័ព្ទ «វប្បធម៌ប្រពៃណី» មិនត្រូវបានកំណត់ ដែលទំនងអាចជានាំឱ្យមានការអនុវត្តច្បាប់តាមអំពើចិត្ត។ ជាក់ស្តែង ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មានសិល្បករជាច្រើនរូប ត្រូវបានចាប់ខ្លួន ដោយសារតែស្នាដៃសិល្បៈ ឬចំរៀងរបស់ពួកគាត់ ត្រូវបានអាជ្ញាធររាជរដ្ឋាភិបាលចាត់ទុកថាបំពាននឹងវប្បធម៌ និងប្រពៃណីរបស់ខ្មែរ។ សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ រួមបញ្ចូលទាំងសិទ្ធិមិនពេញចិត្ត ប្រតិកម្ម និងរំខាន។

[22] កថាខណ្ឌទី ៤៣ នៃ «របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ ដោយ Frank La Rue» ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១២ ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/67/357

- *បង្កគ្រោះថ្នាក់ដល់ការការពារជាតិ ឬសន្តិសុខជាតិ*
  បទប្បញ្ញត្តិស្របច្បាប់ដែលហាមឃាត់សេចក្តីថ្លែង ឬខ្លឹមសារអនឡាញដែល «បង្កគ្រោះថ្នាក់ដល់ការការពារជាតិ ឬសន្តិសុខជាតិ» ត្រូវបានប្រើប្រាស់សម្រាប់រឹតត្បិតដោយមិនស្របច្បាប់ និងផ្តន្ទាទោសដល់ការរិះគន់រដ្ឋាភិបាល ដែលផ្ទុយទៅនឹងមាត្រា ១៩ នៃកតិកាសញ្ញា ICCPR ។[23] លក្ខខណ្ឌមិនច្បាស់លាស់ទាំងនេះ បើកឱ្យមានការបកស្រាយជាច្រើន ហើយផ្តល់នូវឆន្ទានុសិទ្ធិទូលាយដល់រដ្ឋាភិបាលក្នុងការដាក់ទោសសកម្មភាពល្មើសច្បាប់របស់បុគ្គល ដោយមូលហេតុស្រេចតែអំពើចិត្ត និងអត្តនោម័ត។

ចំណាត់ប្រភេទនៃការនិយាយស្តីដែលត្រូវបានហាមឃាត់ នៅក្នុងមាត្រា ៤៥ នៃសេចក្តីព្រាងច្បាប់មិនបានអនុញ្ញាតគ្រប់គ្រាន់ឱ្យអ្នកប្រើប្រាស់អ៊ិនធើណិត ឬ សូម្បីតែអាជ្ញាធររដ្ឋាភិបាលអាចដឹងពីខ្លឹមសារបែបណាដែលត្រូវបានអនុញ្ញាត ឬមិនអនុញ្ញាតឱ្យមាននៅលើប្រព័ន្ធអ៊ិនធើណិតនោះទេ។ នៅពេលដែលមន្ត្រីរាជការទទួលបានឆន្ទានុសិទ្ធិគ្មានដែនកំណត់ក្នុងការកំណត់ថាការនិយាយស្តីបែបណាដែលត្រូវបានអនុញ្ញាតនោះ ការគម្រាមកំហែងយ៉ាងធ្ងន់ធ្ងរទៅលើការនិយាយស្តីដោយសេរី នឹងអាចកើតមាន ជាពិសេសនៅពេលដែលការនិយាយស្តីទាំងនោះនិយាយរិះគន់ប៉ះពាល់ដល់អាជ្ញាធររដ្ឋាភិបាល។ ចំណាត់ប្រភេទមិនច្បាស់លាស់នៃខ្លឹមសារដែលហាមឃាត់នៅក្នុងមាត្រា ៤៥ នៃសេចក្តីព្រាងច្បាប់ មិនបំពេញតាម ចំណុចទី ១ នៃការធ្វើតេស្តទាំងបីចំណុច តាមមាត្រា ១៩ នៃកតិកាសញ្ញា ICCPR នោះទេ ដោយសារមូលហេតុមិនច្បាស់លាស់ ហើយប្រសិនបើសេចក្តីព្រាងច្បាប់នេះត្រូវបានអនុម័តវិញ វាទំនងជាអាចនាំឱ្យមានការត្រួតត្រាទៅលើការនិយាយស្តីដែលស្របច្បាប់មិនខាន។

## ទោសបញ្ញត្តិមិនសមមាត្រ

ទោសបញ្ញត្តិដែលមានចែងនៅក្នុងមាត្រា ៤៥ នៃសេចក្តីព្រាងច្បាប់ មានភាពមិនសមាមាត្រទៅនឹងអន្តរាយដែលអាចបង្កឡើង ហេតុដូច្នេះមាត្រា ៤៥ នៃសេចក្តីព្រាងច្បាប់មិនបំពេញតាមការធ្វើតេស្តទាំងបីចំណុច តាមមាត្រា ១៩ នៃកតិកាសញ្ញា ICCPR នោះទេ។ គោលការណ៍នៃភាពចាំបាច់ និងភាពសមាមាត្រ តម្រូវថាការផ្តន្ទាទោសគឺជាមធ្យោបាយដែលតឹងរឹងតិចបំផុតសម្រាប់

[23] កថាខណ្ឌទី ១៣, ១៩-៣២ នៃ «របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ ដោយ David Kaye» ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៦ ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/71/373

ផ្ទុសផ្ទុលដល់អន្តរាយដែលកើតមាន។ ម្យ៉ាងវិញទៀត ទោសបញ្ញត្តិត្រូវតែជាមធ្យោបាយដែលតឹងរឹងតិចបំផុតក្នុងការសម្រេចបាននូវគោលដៅជារួម។

មាត្រា ៤៥ នៃសេចក្តីព្រាងច្បាប់ចែងពីទោសបញ្ញត្តិជាបទឧក្រិដ្ឋ រួមមានការផាកពិន័យជាប្រាក់យ៉ាងច្រើនសន្ធឹក (រហូតដល់ ៥០ លានរៀល) និងដាក់ពន្ធនាគាររហូតដល់ ៥ ឆ្នាំ។ ការផ្តន្ទាទោសទាំងនេះគឺជាការផ្តន្ទាទោសធ្ងន់ធ្ងរហួសហេតុសម្រាប់ការចែករំលែកព័ត៌មាន គំនិត និងយោបល់ ហើយមិនសមាមាត្រទៅនឹងអន្តរាយដែលបង្កពីការនិយាយស្តីដែលចាត់ទុកថាក្លែងក្លាយនោះទេ។

**អនុសាសន៍៖** ដូចបានលើកឡើងខាងលើ មាត្រា ៤៥ នៃសេចក្តីព្រាងច្បាប់អនុញ្ញាតឱ្យរាជរដ្ឋាភិបាលកម្ពុជាបំបិទ និងហាមឃាត់យ៉ាងមានប្រសិទ្ធភាពទៅលើការនិយាយស្តីណាដែលរាជរដ្ឋាភិបាលកម្ពុជាមិនចូលចិត្ត។ ច្បាប់ដែលផ្តន្ទាទោសជាបទឧក្រិដ្ឋ នូវ «ព័ត៌មានក្លែងក្លាយ» ឬដែលហាមឃាត់ «ដំណឹងក្លែងក្លាយ» រំលោភបំពាននឹងច្បាប់អន្តរជាតិ។ ដើម្បីអនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ មាត្រា ៤៥ នៃសេចក្តីព្រាងច្បាប់ និងចំណាត់ប្រភេទការនិយាយស្តីដែលត្រូវបានហាមឃាត់ គួរតែត្រូវបានលុបចោល។ ប្រសិនបើការហាមឃាត់ប្រភេទខ្លឹមសារជាក់លាក់ គឺជាការចាំបាច់ក្នុងការការពារសិទ្ធិ និងកេរ្តិ៍ឈ្មោះរបស់អ្នកដទៃ សន្តិសុខជាតិ ឬសណ្តាប់ធ្នាប់សាធារណៈ សុខមាលភាព ឬសីលធម៌សាធារណៈ ចំណាត់ប្រភេទនៃខ្លឹមសារដែលត្រូវហាមឃាត់ ត្រូវធ្វើការកំណត់ឡើងវិញ ដើម្បីអនុលោមតាមគោលការណ៍នៃការសន្មតទុកជាមុនបាន និងមានតម្លាភាព។

## *មាត្រា ៤០ នៃសេចក្តីព្រាងច្បាប់*

មាត្រា ៤០ នៃសេចក្តីព្រាងច្បាប់ហាមឃាត់ជនណាម្នាក់មិនឱ្យ «បង្កជាការរុកគួន ការព្រមាន ការគម្រាមកំហែង ការបំពាន ការធ្វើទុក្ខបុកម្នេញ ឬការជេរប្រមាថបុគ្គលម្នាក់ទៀតដោយប្រើប្រាស់មធ្យោបាយទាក់ទងនឹងកុំព្យូទ័រ ។»[24]

ចំណាត់ថ្នាក់ប្រភេទនៃខ្លឹមសារដែលហាមឃាត់ទាំងនេះ មានលក្ខណៈមិនច្បាស់លាស់ និងទូលាយពេកក្នុងការបំពេញតាម គោលការណ៍នៃ «ការកំណត់ដោយច្បាប់» នៃការធ្វើតេស្តចំណុច

[24] មាត្រា ៤០ នៃសេចក្តីព្រាងច្បាប់៖ ការបំពានដោយប្រើកុំព្យូទ័រ «ជនណាម្នាក់ដែលបង្កដោយចេតនាដល់ការរុកគួន ការព្រមាន ការគម្រាមកំហែង ការបំពាន ការធ្វើទុក្ខបុកម្នេញ ឬការជេរប្រមាថបុគ្គលម្នាក់ទៀតដោយប្រើប្រាស់មធ្យោបាយទាក់ទងនឹងកុំព្យូទ័រ ត្រូវពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀល ទៅ ៥ ០០០ ០០០ (ប្រាំលាន) រៀល។ ក្នុងករណីបណ្តាលឱ្យមានការអន្តរាយធ្ងន់ធ្ងរ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ ខែ ទៅ ៦ ខែ និងពិន័យជាប្រាក់ពី ៥ ០០០ ០០០ (ប្រាំលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល។»

ទាំងបី តាមមាត្រា ១៩ នៃកតិកាសញ្ញា ICCPR ដោយហេតុថាគ្មានជនណាម្នាក់អាចទាយទុកមុនបានដោយមានហេតុផលត្រឹមត្រូវថា ការធ្វើសេចក្តីថ្លែង ឬបង្ហើតខ្លឹមសារ ត្រូវបានចាត់ទុកថា «បង្កឱ្យមានការព្រមាន» ទៅលើជនណាម្នាក់នោះទេ។ ដូចគ្នានេះដែរ វាក្យស័ព្ទដូចជា «ការបំពាន» និង«ការធ្វើទុក្ខបុកម្នេញ» មានលក្ខណអត្តនោម័ត និងបើកចំហឱ្យមានការបកស្រាយជាច្រើនហើយ ផ្តល់ឆន្ទានុសិទ្ធិទូលាយដល់រដ្ឋាភិបាលក្នុងការផ្តន្ទាទោសសកម្មភាពឧក្រិដ្ឋកម្មណាមួយទៅលើបុគ្គល តាមអំពើចិត្ត និងបែបអត្តនោម័ត។ ការនិយាយស្តីស្របតាមច្បាប់ជាច្រើន អាចត្រូវបានបកស្រាយថាជាការរំលោភបំពាននឹងមាត្រា ៤០ នៃសេចក្តីព្រាងច្បាប់។ ជាពិសេសនោះគឺសម្រាប់ការនិយាយស្តីដែលសំដៅរិះគន់ស្ថាប័ន ឬបុគ្គលក្នុងជួររាជរដ្ឋាភិបាល ឬគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា។ សិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ រួមបញ្ចូលសិទ្ធិក្នុងការត្រួតត្រា ការពិភាក្សាដោយបើកចំហ ការធ្វើសេចក្តីថ្លែងដែលមានលក្ខណៈមិនពេញចិត្ត ប្រតិកម្ម រំខាន និងរិះគន់។

**អនុសាសន៍៖** ដើម្បីអនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ គួរលុបចោលមាត្រា ៤០ នៃសេចក្តីព្រាងច្បាប់។

## ការព្យួរ ឬការដកអាជ្ញាប័ណ្ណ និង "ការផាកពិន័យអន្តរកាល" ដែលមិនច្បាស់លាស់ គម្រាមកំហែងដល់សង្គមស៊ីវិល និងអាជីវកម្មនានា

**បញ្ហា៖** មាត្រា ៦ នៃសេចក្តីព្រាងច្បាប់ ផ្តល់សិទ្ធិអំណាចដល់ក្រសួងមហាផ្ទៃក្នុងការចេញសេចក្តីព្រមាន និង «ផាកពិន័យអន្តរកាល»។ ក្រសួងមហាផ្ទៃក៏ទទួលបាននូវសិទ្ធិអំណាចក្នុងការស្នើសុំដីកាតុលាការ ស្តីពីការព្យួរសកម្មភាពរបស់អង្គការ និងអាជីវកម្មណាមួយជាបណ្តោះអាសន្ន ក្នុងករណី «មិនរាងចាល»។[25] ក៏ប៉ុន្តែ មាត្រា ៦ នៃសេចក្តីព្រាងច្បាប់ មិនបានចែងពីចំនួនទឹកប្រាក់ពិន័យ ឬពីរបៀបដែលក្រសួងមហាផ្ទៃកំណត់ពី «ការមិនរាងចាល» នោះទេ។

[25] មាត្រា ៦ នៃសេចក្តីព្រាងច្បាប់៖ សមត្ថកិច្ចក្នុងការចេញសេចក្តីព្រមាន ឬផាកពិន័យអន្តរកាល៖ «មន្ត្រីនគរបាលយុត្តិធម៌ នៃអគ្គស្នងការនគរបាលជាតិនៃក្រសួងមហាផ្ទៃ ដែលទទួលបន្ទុកប្រឆាំងនឹងឧក្រិដ្ឋកម្មបច្ចេកវិទ្យា មានសមត្ថកិច្ចក្នុងការចេញសេចក្តីព្រមាន និងផាកពិន័យអន្តរកាល។ ក្នុងករណីមិនរាងចាល មន្ត្រីនគរបាលយុត្តិធម៌មានសមត្ថកិច្ច អាចស្នើសុំដីកាតុលាការដើម្បីព្យួរសកម្មភាព ឬអាជីវកម្មណាមួយជាបណ្តោះអាសន្នបាន។»

គួរឱ្យកត់សម្គាល់ផងដែរ មាត្រា ២២ នៃសេចក្តីព្រាងច្បាប់ ចែងថាបទល្មើសបច្ចេកវិទ្យាព័ត៌មានខ្លះ អាចត្រូវបានផ្តន្ទាទោស ដោយការផាកពិន័យអន្តរកាលតាមរយៈអនុក្រឹត្យ ហើយការបង់ប្រាក់ផាកពិន័យនោះ នឹងរំលត់សកម្មភាពព្រហ្មទណ្ឌ។[26]

មាត្រា ៧ នៃសេចក្តីព្រាងច្បាប់ ផ្តល់សិទ្ធិអំណាចដល់ស្ថាប័ន ឬក្រសួងដែលផ្តល់អាជ្ញាប័ណ្ណអាជីវកម្ម វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាត ក្នុងការព្យួរ ឬដកហូតអាជ្ញាប័ណ្ណនោះបាន ប្រសិនបើមានការប្រព្រឹត្តបទល្មើស។[27]

**ការវិភាគ៖** មាត្រា ៦ មាត្រា៧ និង មាត្រា ២២ នៃសេចក្តីព្រាងច្បាប់ ផ្តល់សិទ្ធិអំណាចធំធេង និងគ្មានការត្រួតពិនិត្យទៅឱ្យក្រសួងមហាផ្ទៃ និងក្រសួងផ្សេងទៀត ដែលអាចប្រើសម្រាប់សំដៅទៅលើសង្គមស៊ីវិល និងអាជីវកម្មផ្សេងទៀត។

ជាដំបូង ក្រសួងមហាផ្ទៃ និងក្រសួងពាក់ព័ន្ធ ទទួលបានសិទ្ធិអំណាចក្នុងការព្យួរ ឬបិទសកម្មភាពអង្គការ និងអាជីវកម្ម។ ការបិទអាជីវកម្ម ឬអង្គការ ទំនងជាទោសទណ្ឌមិនសមស្របមួយក្រោមច្បាប់អន្តរជាតិ ជាពិសេសប្រសិនបើ «បទល្មើស» មានពាក់ព័ន្ធជាមួយនឹងការនិយាយស្តីនៅលើប្រព័ន្ធអ៊ិនធើណិត។[28]

---

[26] មាត្រា ២២ នៃសេចក្តីព្រាងច្បាប់៖ ទោសពិន័យអន្តរកាល "បទល្មើសបច្ចេកវិទ្យាព័ត៌មានដែលអាចផ្តន្ទាទោសដោយទោសបញ្ញត្តិអន្តរការល ត្រូវកំណត់ដោយអនុក្រឹត្យ។ ការបង់ប្រាក់ពិន័យអន្តរកាល ត្រូវរំលត់សកម្មភាពព្រហ្មទណ្ឌ។"

[27] មាត្រា ៧ នៃសេចក្តីព្រាងច្បាប់៖ សមត្ថកិច្ចក្នុងការដកហូតសិទ្ធិធ្វើអាជីវកម្ម/អាជ្ញាប័ណ្ណអាជីវកម្ម- "ស្ថាប័នមានសមត្ថកិច្ចដែលចេញអាជ្ញាប័ណ្ណអាជីវកម្ម វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាត អាចព្យួរ ឬដកហូតអាជ្ញាប័ណ្ណ វិញ្ញាបនបត្រ ឬលិខិតអនុញ្ញាត ប្រសិនបើប្រតិបត្តិករអាជីវកម្មប្រព្រឹត្តបទល្មើសដែលមានចែងនៅក្នុងច្បាប់នេះ។ "

[28] **កថាខណ្ឌទី ៣៦** នៃ «របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ ដោយ Frank La Rue" ចុះថ្ងៃទី៦ ខែឧសភា ឆ្នាំ២០១១ ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/17/27៖ «ការដាក់ពន្ធនាគារជនដែលស្វែងរក ទទួលបាន និងចែករំលែកព័ត៌មាន និងគំនិត អាចត្រូវបានផ្ទៀងផ្ទាត់ដោយកម្រ ថាជាវិធានការសមស្របក្នុងការសម្រេចបាននូវគោលដៅស្របច្បាប់មួយក្រោមកថាណ្ឌទី ៣ មាត្រា ១៩ នៃកតិកាសញ្ញា ICCPR»។ សូមមើលផងដែរ **កថាខណ្ឌទី ៣៣** នៃ «របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ ដោយ David Kaye» ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៦ ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/71/373។ **កថាខណ្ឌទី ៣៩-៤៣** នៃ «របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ ដោយ Ambeyi Ligabo» ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០០៨ ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/HRC/7/14។

ដូចគ្នានេះដែរ ការបិទអង្គភាព មិនស៊ីសង្វាក់ទៅនឹងសេរីភាពខាងសមាគមនោះទេ។ ការរំលាយដោយមិនស្ម័គ្រចិត្ត គឺជាដំណោះស្រាយចុងក្រោយបំផុតដែលប្រើសម្រាប់តែការបំពានធ្ងន់ធ្ងរបំផុត និងជាទូទៅបន្ទាប់ពីមានការជូនដំណឹង និងផ្តល់ឱកាសឱ្យកែតម្រូវភាពខ្វះចន្លោះ៖

> ការព្យួរ និងការរំលាយអង្គការមួយដោយមិនស្ម័គ្រចិត្ត គឺជាប្រភេទរឹតត្បិតដ៏ធ្ងន់ធ្ងរបំផុតទៅលើសេរីភាពខាងសមាគម។ ជាលទ្ធផល វាអាចធ្វើទៅរួចនៅពេលមានគ្រោះថ្នាក់ច្បាស់លាស់ និងជិតកើតមាន ដែលបណ្តាលមកពីការបំពានជាក់ស្តែងទៅលើច្បាប់ជាតិ ដោយអនុលោមតាមច្បាប់សិទ្ធិមនុស្សអន្តរជាតិ។ ការព្យួរ និងការរំលាយនោះ ត្រូវសមាមាត្រយ៉ាងតឹងរឹងទៅនឹងគោលដៅស្របច្បាប់ដែលកំពុងធ្វើ និងប្រើប្រាស់សម្រាប់តែនៅពេលដែលវិធានការទន់ភ្លន់ជាងនេះ មិនអាចធ្វើទៅបានគ្រប់គ្រាន់តែប៉ុណ្ណោះ។[29]

គ្រប់ស្ថាប័នសារព័ត៌មាន អង្គការសង្គមស៊ីវិល និងស្ថាប័នឯកជនទាំងអស់ អាចស្ថិតក្នុងភាពគ្រោះថ្នាក់ ប្រឈមមុខនឹងការបិទស្ថាប័ន ប្រសិនបើបុគ្គលិកណាម្នាក់ធ្វើ ឬផ្សព្វផ្សាយសេចក្តីថ្លែងដែលបំពាននឹងខ្លឹមសារដែលត្រូវបានរឹតត្បិតបែបទូលាយ និងមិនច្បាស់លាស់សោះនោះ។ អាស្រ័យទៅតាមការបកស្រាយច្បាប់ អង្គការត្រូវទទួលខុសត្រូវ បើទោះបីជាបុគ្គលិករបស់អង្គការជាអ្នកធ្វើសកម្មភាពក្រៅវង្វង់តួនាទី និងភារកិច្ចផ្លូវការរបស់គាត់ ដោយបានធ្វើសេចក្តីថ្លែងដែលមិនស្របច្បាប់ខាងលើ។ សកម្មភាពរបស់រដ្ឋាភិបាលចំពោះសមាគម ត្រូវតែមានភាពសមាមាត្រ។[30] ការរំលាយ ឬបិទអាជីវកម្ម អង្គការ ឬស្ថាប័នស្របច្បាប់ផ្សេង មិនមែនជាទោសទណ្ឌដែលសមាមាត្រទៅនឹងបទល្មើសព្រហ្មទណ្ឌជាច្រើនដែលមានចែងនៅក្នុងសេចក្តីព្រាងច្បាប់។

---

[29] កថាខណ្ឌទី ៧៥ នៃ «របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ ដោយ Maina Kiai» ចុះថ្ងៃទី១២ ខែឧសភា ឆ្នាំ២០១២ ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/HRC/20/27។

[30] សូមមើល ទំព័រទី ២៣ នៃ «របាយការណ៍របស់អ្នកតំណាងពិសេសនៃអគ្គលេខាធិការ ស្តីពីអ្នកការពារសិទ្ធិមនុស្ស ដោយ Hina Jilani ដោយអនុលោមតាមសេចក្តីសម្រេចរបស់មហាសន្និបាតលេខ 58/178" ចុះថ្ងៃទី១ ខែតុលា ឆ្នាំ២០០៤ ឯកសាររបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ A/59/401។ សូមមើលផងដែរ៖ កថាខណ្ឌទី ៣៨ នៃ «របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីសិទ្ធិសេរីភាពក្នុងការប្រមូលផ្តុំដោយសន្តិវិធី និងខាងសមាគម ដោយ Maina Kiai» ចុះថ្ងៃទី២៤ ខែមេសា ឆ្នាំ២០១៣ ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/HRC/23/39។

ទី២ ដោយសារតែចំនួនទឹកប្រាក់ផាកពិន័យនឹងត្រូវបានកំណត់នៅក្នុងអនុក្រឹត្យនាពេលក្រោយ គ្មាននរណាម្នាក់ដឹងពីវិសាលភាពពេញលេញនៃការរំលោភបំពានច្បាប់នោះទេ។[31] អនុក្រឹត្យ អាចកំណត់ពីការផាកពិន័យច្រើនសន្ធឹកសន្ធាប់ ដែលអង្គការសង្គមស៊ីវិល និងអាជីវកម្មជាច្រើនមិនអាចបង់បាន។ យើងអាចប្រមើលបានថា អង្គការ ឬស្ថាប័នទាំងនោះ អាចបាត់បង់អាជ្ញាប័ណ្ណ ឬលិខិតអនុញ្ញាតឱ្យធ្វើសកម្មភាពបាន។

ទី ៣ គ្មានចំណុចចាប់ផ្ដើម ឬលក្ខខណ្ឌវិនិច្ឆ័យណាមួយសម្រាប់ឱ្យក្រសួងមហាផ្ទៃចេញសេចក្ដីព្រមាន ឬការផាកពិន័យអន្តរកាលណាមួយនោះទេ។ ជាហេតុធ្វើឱ្យក្រសួងមហាផ្ទៃមានសិទ្ធិជ្រើសរើសបានតាមអំពើចិត្ត ក្នុងការចេញសេចក្ដីព្រមាន ឬការផាកពិន័យ ដោយហេតុផលអត្តនោម័ត និងគ្មានតម្លាភាព។

ការផ្ដន្ទាទោសបទល្មើស មិនត្រូវធ្វើឡើង ដរាបណាមានការកំណត់ពីពិរុទ្ធភាពដោយស្ថាប័នតុលាការតាមផ្លូវច្បាប់។ ហើយស្ថាប័នតុលាការ ត្រូវកំណត់ពីទណ្ឌកម្មចំពោះបទល្មើសព្រហ្មទណ្ឌណាមួយ និងទាំងអស់។ ការអនុញ្ញាតឱ្យក្រសួងមហាផ្ទៃ និងក្រសួងផ្សេងទៀតកំណត់ដោយឯកឯង ថាជាបទល្មើសបច្ចេកវិទ្យាព័ត៌មាន និងនៅពេលណាដែលមានការប្រព្រឹត្តបទល្មើសបច្ចេកវិទ្យាព័ត៌មាន ព្រមទាំងទោសទណ្ឌអ្វីដែលសមស្រប អាចទំនងជាការរំលោភបំពាននឹងច្បាប់អន្តរជាតិ។

អនុសាសន៍៖ ដើម្បីអនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ គួរលុបចោល មាត្រា ៦ និងមាត្រា ៧ នៃសេចក្ដីព្រាងច្បាប់។ ការផាកពិន័យ គឺជាផ្នែកមួយនៃបញ្ញត្តិព្រហ្មទណ្ឌមួយចំនួននៅក្នុងសេចក្ដីព្រាងច្បាប់។ ប្រសិនបើរាជរដ្ឋាភិបាលកម្ពុជា យល់ថាត្រូវព្យួរ ឬបិទទ្វារអង្គការ/ស្ថាប័ន ដោយសារមូលហេតុនៃការរំលោភបំពាននឹងសេចក្ដីព្រាងច្បាប់ ការផ្ដន្ទាទោសទាំងនេះ ត្រូវមានចែងនៅក្នុងបញ្ញត្តិព្រហ្មទណ្ឌពាក់ព័ន្ធ ហើយមានតែស្ថាប័នតុលាការប៉ុណ្ណោះដែលអាចអនុញ្ញាតឱ្យកំណត់ទោសទណ្ឌចំពោះបទល្មើសព្រហ្មទណ្ឌដែលប្រព្រឹត្តផ្ទុយនឹងសេចក្ដីព្រាងច្បាប់។

## ចាំបាច់ត្រូវមានការត្រួតពិនិត្យតាមផ្លូវតុលាការ ទើបជាការប្រសើរ

**បញ្ហាទី១៖** មាត្រា ១២-១៦ នៃសេចក្ដីព្រាងច្បាប់ កំណត់ពីនីតិវិធីតម្រូវឱ្យអាជ្ញាធរអនុវត្តតាមនៅពេលស្វែងរក រឹបអូស និងស្ទាក់ចាប់យកទិន្នន័យ និងបញ្ជាឱ្យមានការរក្សាទុក និងការផលិត

[31] សូមមើល មាត្រា ២២ នៃសេចក្ដីព្រាងច្បាប់៖ ការផាកពិន័យអន្តរកាល «បទល្មើសបច្ចេកវិទ្យាព័ត៌មានដែលអាចត្រូវបានផ្ដន្ទាទោសដោយការផាកពិន័យជាអន្តរកាល ត្រូវកំណត់ដោយអនុក្រឹត្យ។»

ទិន្នន័យកុំព្យូទ័រ។ សេចក្តីព្រាងច្បាប់ផ្តល់សិទ្ធិអំណាចដល់មន្ត្រីនគរបាលយុត្តិធម៌ និងអគ្គស្នងការនគរបាលជាតិ នៃក្រសួងមហាផ្ទៃ ក្នុងការស៊ើបអង្កេតបទល្មើសបច្ចេកវិទ្យាព័ត៌មាន។[32] សេចក្តីព្រាងច្បាប់នេះ មិនបានចែងពីការត្រួតពិនិត្យនិងការការពារតាមផ្លូវតុលាការឱ្យបានគ្រប់គ្រាន់ ដែលធ្វើឱ្យមានហានិភ័យដល់សិទ្ធិឯកជនភាព និងសេរីភាពក្នុងការបញ្ចេញមតិ។

**ការពិភាក្សា៖** នៅពេលត្រួតពិនិត្យលើមាត្រា ១២-១៦ នៃសេចក្តីព្រាងច្បាប់ទាំងស្រុង វាប្រាកដណាស់ដែលក្រសួងមហាផ្ទៃនឹងមានសិទ្ធិអំណាចធំធេងក្នុងការអង្កេតតាមដានដោយមិនចាំបាច់មានការត្រួតពិនិត្យពីសំណាក់ស្ថាប័នតុលាការនោះទេ។ វាទំនងជាប៉ះពាល់ធ្ងន់ធ្ងរដល់សេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិឯកជនភាពរបស់ប្រជាពលរដ្ឋខ្មែរ និងជនដែលរស់នៅក្នុងប្រទេសកម្ពុជា។

មាត្រា ១២-១៦ នៃសេចក្តីព្រាងច្បាប់ ផ្តល់សិទ្ធិអំណាចស៊ើបអង្កេតបែបទូលាយ និងលាតសន្ធឹងដល់ក្រសួងមហាផ្ទៃ។ ទោះបីជាក្រសួងមហាផ្ទៃអាចអនុវត្តសិទ្ធិអំណាចភាគច្រើនបាន បន្ទាប់ពីមានដីកាចេញពីព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរក្តី ក៏ប៉ុន្តែស្ថាប័នទាំងនេះមិនមែនជាស្ថាប័នតុលាការឯករាជ្យ ដូចតម្រូវតាមច្បាប់អន្តរជាតិនោះទេ។

អំណាចទាំងនេះសំដៅបង្កើតប្រព័ន្ធតាមដានទំនាក់ទំនង។[33] ច្បាប់សិទ្ធិមនុស្សអន្តរជាតិ កំណត់ច្បាស់ថា ការប្រមូល និងការឃាត់ទុកទិន្នន័យទំនាក់ទំនង សំដៅលើការជ្រៀតជ្រែកសិទ្ធិឯកជនភាព។[34] ហេតុដូច្នេះ អនុលោមតាមមាត្រា ១៧ នៃកតិកាសញ្ញា ICCPR រាជរដ្ឋាភិបាលកម្ពុជាត្រូវទទួលខុសត្រូវបង្ហាញថាការតាមដានទំនាក់ទំនងដែលបង្កើតឡើងស្របតាមមាត្រា ១២-១៦

---

32 មាត្រា ៥ នៃសេចក្តីព្រាងច្បាប់៖ អាជ្ញាធរមានសមត្ថកិច្ចក្នុងការស៊ើបអង្កេតបទល្មើសបច្ចេកវិទ្យាព័ត៌មាន «មន្ត្រីនគរបាលយុត្តិធម៌ នៃអគ្គស្នងការនគរបាលជាតិ នៃក្រសួងមហាផ្ទៃ មានសមត្ថកិច្ចក្នុងការស៊ើបអង្កេតបទល្មើសនានាក្រោមច្បាប់នេះ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ ដែលទទួលបន្ទុកប្រឆាំងបទល្មើសបច្ចេកវិទ្យាព័ត៌មាន អាចសហការជាមួយនឹងជំនាញការបច្ចេកទេសជាតិ ឬអន្តរជាតិ ដើម្បីស៊ើបអង្កេតបទល្មើសដែលបានស្នើសុំសហការនោះបាន។»

33 លោក Frank La Rue អតីតអ្នករាយការណ៍ពិសេសស្តីពីសេរីភាពក្នុងការបញ្ចេញមតិ បានកំណត់និយមន័យ «ការតាមដានទំនាក់ទំនង» ថាជា «ការតាមដាន ការស្ទាក់ចាប់ ការប្រមូល ការរក្សាទុក និងការឃាត់ទុកព័ត៌មានដែលបានទាក់ទង បញ្ជូនត ឬបង្កើតនៅលើបណ្តាញគមនាគមន៍»។ សូមមើល កថាខណ្ឌទី ៦៧ នៃ «របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ ដោយ Frank La Rue» ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៣ ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/HRC/23/40។

34 កថាខណ្ឌទី ១៩-២៣ នៃ «របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ ដោយ Frank La Rue» ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៣ ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/HRC/23/40។

នៃសេចក្តីព្រាងច្បាប់ បានបំពេញតាមការធ្វើតេស្តដែលមានកំណត់នៅក្នុងសេចក្តីពន្យល់ទូទៅ លេខ ២៧.១៥។ មាត្រាទាំងនេះទំនងជាមិនបំពេញតាមការធ្វើតេស្ត ដោយសារតែខ្វះវិធានការការពារដែលតម្រូវសម្រាប់ឆ្លងផុតការធ្វើតេស្តនៃភាពសមាមាត្រ។

ក្រោមច្បាប់សិទ្ធិមនុស្សអន្តរជាតិ ការរឹតត្បិតទៅលើសិទ្ធិឯកជនភាព និងសេរីភាពក្នុងការបញ្ចេញមតិ ត្រូវតែបង្ហាញថាជាមធ្យោបាយរឹតត្បិតតិចបំផុត ដើម្បីសម្រេចបាននូវគោលដៅជារួម។ "រដ្ឋត្រូវតែធានាថាសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិឯកជនភាព ស្ថិតនៅជាចំណុចកណ្តាលនៃក្របខណ្ឌការងារតាមដានទំនាក់ទំនង"។[35]

ដើម្បីបំពេញតាមកាតព្វកិច្ចផ្លូវច្បាប់ជាអន្តរជាតិរបស់រដ្ឋសមាជិក នីតិកម្មជាតិ ត្រូវតែ "ចែងថាការតាមដានរបស់រដ្ឋទៅលើទំនាក់ទំនង ត្រូវតែធ្វើឡើងក្រោមស្ថានភាពពិសេសបំផុតប៉ុណ្ណោះ និងផ្តាច់មុខ ក្រោមការគ្រប់គ្រងរបស់អាជ្ញាធរតុលាការឯករាជ្យ។"[36] ការស្នើសុំការអនុញ្ញាតពីស្ថាប័នតុលាការជាមុនដើម្បីអាចមានសិទ្ធិអំណាចតាមដាន គឺការមិនគួរឱ្យតម្រូវនោះទេ ប៉ុន្តែជាការសំខាន់ណាស់សម្រាប់គោរពសេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិឯកជនភាព។

ការតម្រូវឱ្យមានដីកាចេញពីស្ថាប័នតុលាការឯករាជ្យ មុននឹងអាចភ្ជាប់ទៅកាន់ ឬស្វែងរកតាមប្រព័ន្ធកុំព្យូទ័រ និងប្រព័ន្ធគមនាគមន៍អេឡិចត្រូនិចផ្សេងទៀត ឆ្លុះបញ្ចាំងពីការអនុវត្តល្អបំផុត។ ទោះជាយ៉ាងណាក្តី ដីកាត្រូវមានវិធានការការពារ ដើម្បីកុំឱ្យមានការបំពានសិទ្ធិរបស់បុគ្គល។

ទី១ ដីកាសម្រាប់ការផលិត ការប្រមូល ឬការស្ទាក់ចាប់ទិន្នន័យកុំព្យូទ័រ ត្រូវមានវិសាលភាពតូចចង្អៀត និងសម្រាប់រយៈពេលកំណត់ណាមួយជាក់លាក់ប៉ុណ្ណោះ។ ច្បាប់សិទ្ធិមនុស្សអន្តរជាតិតម្រូវថារយៈពេលស្ទាក់ចាប់ ត្រូវមានកម្រិត មិនអាចពន្យារពេលដោយគ្មានកំណត់នោះទេ ហើយត្រូវធ្វើឡើងដោយមានការបង្ហាញពីភាពចាំបាច់នៃការស្ទាក់ចាប់នោះ។

ទី២ វិសាលភាពទិន្នន័យដែលត្រូវប្រមូលយក ត្រូវតែមានកំណត់និយមន័យឱ្យបានច្បាស់ និងពាក់ព័ន្ធទៅនឹងការប្រព្រឹត្តសកម្មភាពល្មើសដែលបានលើកឡើង។ ប្រសិនបើគ្មានលក្ខខណ្ឌតម្រូវនេះ

---

[35] កថាខណ្ឌទី ៨០ នៃ «របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ ដោយ Frank La Rue» ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៣ ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/HRC/23/40។

[36] កថាខណ្ឌទី ៨១ នៃ «របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ ដោយ Frank La Rue» ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៣ ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/HRC/23/40។

ទេ ភាពអាចកើតមាននៃការរំលោភបំពានសិទ្ធិឯកជនភាព នឹងកើនឡើង ដោយសារតែអាជ្ញាធរ អាចប្រមូលព័ត៌មានណាមួយ និងទាំងអស់របស់បុគ្គល ទោះបីជាព័ត៌មាននោះមិនមានទំនាក់ទំនងដោយផ្ទាល់ជាមួយនឹងសកម្មភាពឧក្រិដ្ឋដែលកំពុងស្ថិតក្រោមការសង្ស័យក្តី។

ទី ៣ ចំណុចចាប់ផ្តើមតាមផ្លូវតុលាការ ក្នុងការចេញដីកាដើម្បីអាចតាមដាន ឬប្រមូលទិន្នន័យ ត្រូវតែស្ថិតក្នុងកម្រិត ខ្ពស់គ្រប់គ្រាន់ ដោយមិនសំដៅត្រឹមការអនុញ្ញាតតាមព្រឹត្តិហេតុនោះទេ។ ចំណុចចាប់ផ្តើមក្នុងកម្រិតទាប ដូចជាការសំអាងតែលើ «មូលហេតុសមហេតុផលគួរឱ្យជឿបាន» ឬ«មូលហេតុសមហេតុផលដោយមានភស្តុតាងបញ្ជាក់ថាមានបទល្មើស» សំដៅដល់ការអនុញ្ញាតតាមព្រឹត្តិហេតុ នៃសំណើសុំអនុវត្តច្បាប់ ដែលអាចនាំឱ្យ ឬរួមចំណែកឱ្យមានការរឹតត្បិតមិនអាចទទួលយកបានទៅលើសេរីភាពក្នុងការបញ្ចេញមតិ។[37]

បន្ថែមពីលើនេះ ក្រោមច្បាប់អន្តរជាតិ ត្រូវបង្កើតឱ្យមានវិធានការការពារមួយសំណុំ ដើម្បីធានាថាប្រព័ន្ធតាមដានទំនាក់ទំនង អនុលោមតាមកតិកាសញ្ញា ICCPR។ «វិធានការការពារត្រូវតែមានចែងនៅក្នុងច្បាប់ ដោយមានកំណត់ពីលក្ខខណ្ឌ វិសាលភាព និងរយៈពេលនៃការចាត់វិធានការដែលអាចធ្វើទៅរួច មូលហេតុត្រឹមត្រូវសម្រាប់ចាត់វិធានការទាំងនោះ អាជ្ញាធរមានសមត្ថកិច្ចក្នុងការផ្តល់ការអនុញ្ញាត ការអនុវត្ត និងការគ្រប់គ្រង ព្រមទាំងប្រភេទដំណោះស្រាយដែលផ្តល់ដោយច្បាប់ជាតិ។»[38] វិធានការការពារទាំងនេះរួមមាន៖

- បទល្មើស និងសកម្មភាពពាក់ព័ន្ធនឹងការតាមដាន ត្រូវតែមានភាពច្បាស់លាស់ និងជាក់លាក់
- ច្បាប់ត្រូវតែចង្អុលបង្ហាញយ៉ាងច្បាស់ ថាមនុស្សបែបណាដែលអាចត្រូវរងការតាមដាន
- ត្រូវមានពេលវេលាកំណត់តឹងរឹង សម្រាប់ការអនុវត្តប្រតិបត្តិការតាមដាន
- ត្រូវកំណត់នីតិវិធីតឹងរឹង សម្រាប់បង្គាប់បញ្ជាឱ្យ ត្រួតពិនិត្យ ប្រើប្រាស់ និងរក្សាទុកទិន្នន័យដែលទទួលបាន នៅក្នុងដំណើរការតាមដាន

---

37 កថាខណ្ឌទី ៥៦ នៃ «របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ ដោយ Frank La Rue» ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៣ ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/HRC/23/40។

38 កថាខណ្ឌទី ៨១ នៃ «របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ ដោយ Frank La Rue» ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៣ ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/HRC/23/40។

- ត្រូវមានវិធានតឹងរឹងស្តីពីការកំទេច ឬការលុបចោលទិន្នន័យដែលរងការតាមដាន ដើម្បីបង្ការកុំឱ្យមានការលាក់បាំងព័ត៌មាននៅសេសសល់ក្រោយពីរកឃើញការពិត
- ស្ថាប័នដែលទទួលបន្ទុកគ្រប់គ្រងការប្រើប្រាស់អំណាចតាមដាន ត្រូវតែជាស្ថាប័នឯករាជ្យ និងមានការទទួលខុសត្រូវចំពោះ និងត្រូវតែងតាំងដោយ ស្ថាប័ននីតិបញ្ញត្តិ ជាជាងស្ថាប័ននីតិប្រតិបត្តិ។[39]

ជាចុងក្រោយ ការអនុវត្តល្អបំផុត តម្រូវឱ្យមានយន្តការច្បាប់ ដែលវិធានការស៊ើបអង្កេតទាំងនេះអាចត្រូវបានតវ៉ាដេញដោលដោយបុគ្គល និង/ឬ អ្នកផ្តល់សេវាដែលទទួលរងផលប៉ះពាល់។[40]

## មាត្រា ១២ (១) នៃសេចក្តីព្រាងច្បាប់

មាត្រា ១២(១) នៃសេចក្តីព្រាងច្បាប់តម្រូវឱ្យអ្នកផ្តល់សេវារក្សាទុកភ្លាមៗនូវទិន្នន័យកុំព្យូទ័រ ទិន្នន័យចរាចរណ៍ ឬព័ត៌មានអ្នកប្រើប្រាស់ នៅពេលមានសំណើពីក្រសួងមហាផ្ទៃ ក្នុងករណីដែល «មានមូលហេតុសមហេតុផល ថាភស្តុតាងបទល្មើសអាចរកបាននៅលើប្រព័ន្ធកុំព្យូទ័ររបស់អ្នកផ្តល់សេវា ឬក្រោមការត្រួតត្រារបស់អ្នកផ្តល់សេវា។»[41] ស្របតាមមាត្រា ១២(២) នៃសេចក្តីព្រាង

---

39 *សូមមើល កថាខណ្ឌទី ៣៧ នៃការវិភាគផ្នែកច្បាប់ជាសកល របស់អង្គការសម្ព័ន្ធ Necessary and Proportionate (ខែឧសភា ឆ្នាំ ២០១៤) ដែលអាចរកមើលបានតាម http://necessaryandproportionat.org/global-legal-analysis; ដោយដកស្រង់ករណីសិក្សា Klass and Others v. ប្រទេសអាល្លឺម៉ង់ លេខ 5029/71 ចុះថ្ងៃទី ៦ ខែកញ្ញា ឆ្នាំ១៩៧៨; ករណី Liberty and Others v. ចក្រភពអង់គ្លេស លេខ 58243/00 ចុះថ្ងៃទី ១ ខែកក្កដា ឆ្នាំ២០០៨ និងករណីសិក្សា Rotary v. ប្រទេសរូម៉ានី លេខ 28341/95 ចុះថ្ងៃទី ៤ ខែឧសភា ឆ្នាំ២០០០ ពាក់ព័ន្ធនឹងការតាមដានធ្វើឡើងដោយភ្នាក់ងារស៊ើបការណ៍សម្ងាត់។*

40 ជាឧទាហរណ៍ សូមមើល កថាខណ្ឌទី ៨ និង ៩ នៃសេចក្តីប្រកាសរួមស្តីពីកម្មវិធីតាមដាន និងផលប៉ះពាល់ទៅលើសេរីភាពក្នុងការបញ្ចេញមតិ ចេញដោយអ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ និងចេញដោយអ្នករាយការណ៍ពិសេសសម្រាប់សេរីភាពក្នុងការបញ្ចេញមតិរបស់គណៈកម្មការអន្តរទ្វីបអាមេរិកស្តីពិសិទ្ធិមនុស្ស ខែមិថុនា ឆ្នាំ២០១៣ អាចរកមើលបានតាមរយៈតំណភ្ជាប់៖ http://www.oas.org/en/iachr/expression/showarticle.asp?artID=927&lID=1.

41 មាត្រា ១២ នៃសេចក្តីព្រាងច្បាប់៖ ការរក្សាទុកទិន្នន័យកុំព្យូទ័រ និងទិន្នន័យចរាចរណ៍ «តាមការស្នើសុំពីអាជ្ញាធរមានសមត្ថកិច្ចក្នុងការប្រមូលភស្តុតាង ប្រសិនបើមានមូលហេតុសមហេតុផល ថាភស្តុតាងបទល្មើសអាចរកបាននៅលើប្រព័ន្ធកុំព្យូទ័ររបស់អ្នកផ្តល់សេវា ឬក៏ក្រោមការគ្រប់គ្រងរបស់អ្នកផ្តល់សេវា អ្នកផ្តល់សេវាត្រូវរក្សាទុកភាល់ទិន្នន័យកុំព្យូទ័រ ទិន្នន័យចរាចរណ៍ ឬព័ត៌មានពាក់ព័ន្ធរបស់អ្នកប្រើប្រាស់សេវា។ ២. អ្នកផ្តល់សេវាដែលមានកាតព្វកិច្ចរក្សាទុកទិន្នន័យកុំព្យូទ័រ និង/ឬទិន្នន័យចរាចរណ៍ ដែលមានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ ត្រូវរក្សាទុកទិន្នន័យកុំព្យូទ័រ ឬទិន្នន័យចរាចរណ៍ ក្នុងរយៈពេល ១៨០ (មួយរយប៉ែតសិប) ថ្ងៃ។ ក្នុងករណីចាំបាច់ អាជ្ញាធរមានសមត្ថកិច្ចអាចស្នើសុំឱ្យពន្យាពេលរក្សាទុកទិន្នន័យកុំព្យូទ័របានម្តងទៀតប៉ុណ្ណោះសម្រាប់រយៈពេល ១៨០ (មួយរយប៉ែតសិប) ថ្ងៃបន្ថែម។ ៣. ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ អាចចេញដីកាឱ្យរក្សាទុកទិន្នន័យកុំព្យូទ័រពាក់ព័ន្ធនឹងការស៊ើបអង្កេតបទល្មើស នៅដំណាក់កាលណាក៏បានក្នុងដំណើរការនីតិវិធីតុលាការ។ ៤. អ្នកផ្តល់សេវា ឬបុគ្គលណាដែលជាម្ចាស់កម្មសិទ្ធិទិន្នន័យ ដែលមានចែងក្នុងកថាខណ្ឌទី ១ ខាងលើ មានកាតព្វកិច្ចរក្សាទុកព័ត៌មានទាំងនោះប្រកបដោយប្រសិទ្ធភាព ក្នុងលក្ខខណ្ឌរក្សាការសម្ងាត់

ច្បាប់ អ្នកផ្តល់សេវា ត្រូវរក្សាទុកទិន្នន័យក្នុងរយៈពេល ១៨០ ថ្ងៃ ប៉ុន្តែក្រសួងមហាផ្ទៃអាចស្នើសុំពន្យារពេលបន្ថែមបាន ១៨០ ថ្ងៃទៀត។ ស្របតាមមាត្រា ១២ (៣) នៃសេចក្តីព្រាងច្បាប់ ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ ក៏អាចចេញដីកាឱ្យរក្សាទុកទិន្នន័យ តែមិនមានពេលវេលាកំណត់សម្រាប់ការរក្សាទុកតាមដីកានោះទេ។ គួរឱ្យកត់សម្គាល់ មិនតម្រូវឱ្យមានដីកា ឬការត្រួតពិនិត្យតាមផ្លូវតុលាការណាផ្សេងឱ្យមាននោះទេ។

**អនុសាសន៍៖** ដើម្បីអនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ មាត្រា ១២ នៃសេចក្តីព្រាងច្បាប់ គួរត្រូវបានកែសម្រួល ដោយតម្រូវឱ្យមានការត្រួតពិនិត្យតាមផ្លូវតុលាការ មុនពេលរក្សាទុកទិន្នន័យ។ បន្ថែមពីលើនេះ វិសាលភាពទិន្នន័យដែលត្រូវរក្សាទុក គួរត្រូវកម្រិតត្រឹមទិន្នន័យដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌនោះ។ ជាចុងក្រោយ វិធានការការពារជុំវិញការប្រើប្រាស់ សុវត្ថិភាព និងការលុបទិន្នន័យគួរត្រូវបំពេញបន្ថែមនៅក្នុងសេចក្តីព្រាងច្បាប់ផងដែរ។

## មាត្រា ១៣ នៃសេចក្តីព្រាងច្បាប់

មាត្រា ១៣ នៃសេចក្តីព្រាងច្បាប់ផ្តល់សិទ្ធិអំណាចក្នុងការភ្ជាប់ទៅកាន់កំណត់ត្រា ទិន្នន័យ និងព័ត៌មានរបស់អ្នកប្រើប្រាស់ផ្សេងទៀត ដែលគ្រប់គ្រងដោយអ្នកផ្តល់សេវា នៅពេលមានដីកាចេញពីស្ថាប័នអយ្យការ ឬចៅក្រមស៊ើបសួរ។[42] កំណត់ត្រា ទិន្នន័យ និងព័ត៌មានអ្នកប្រើប្រាស់ផ្សេងទៀត ត្រូវតែ "ចាំបាច់សម្រាប់ការស៊ើបអង្កេតបទឧក្រិដ្ឋ"។

**អនុសាសន៍៖** ដើម្បីអនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ មាត្រា ១៣ នៃសេចក្តីព្រាងច្បាប់ គួរត្រូវបានកែសម្រួល ដោយមានរួមបញ្ចូលការការពារពាក់ព័ន្ធនឹងការប្រើប្រាស់ សុវត្ថិភាព និងការលុបទិន្នន័យទាំងនោះ។

---

និងមិនបង្ហាញ ឬធ្វើសកម្មភាពដែលអាចបង្ហាញឱ្យដឹងពីការរក្សាទុកទិន្នន័យនោះទៅដល់អ្នកប្រើប្រាស់សេវា ឬជនសង្ស័យ ឡើយ។ ៥. ប្រសិនបើទិន្នន័យចរាចរណ៍ស្ថិតក្រោមការកាន់កាប់របស់អ្នកផ្តល់សេវាច្រើននាក់ អ្នកផ្តល់សេវាដែលមានចែងក្នុងកថាខណ្ឌទី ៤ ខាងលើ ត្រូវមានកាតព្វកិច្ចផ្តល់ព័ត៌មានចាំបាច់ទាំងឡាយ ដើម្បីកំណត់អត្តសញ្ញាណរបស់អ្នកផ្តល់សេវាដទៃទៀត និងកំណត់គន្លងដែលទំនាក់ទំនងត្រូវបានបញ្ជូន។ ៦. ការស៊ើបអង្កេតបទឧក្រិដ្ឋនៅក្នុងច្បាប់នេះ ត្រូវអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា។"

[42] មាត្រា ១៣ នៃសេចក្តីព្រាងច្បាប់៖ ដីកាឱ្យផ្តល់ទិន្នន័យ៖ "១. នៅពេលមានសំណើជាលាយលក្ខណ៍អក្សរពីសំណាក់មន្ត្រីនគរបាលយុត្តិធម៌ដែលចង្អុលបង្ហាញថា មានមូលហេតុច្បាស់លាស់ក្នុងការជឿជាក់ថាព័ត៌មានរបស់អ្នកជា ឬទិន្នន័យ"

## មាត្រា ១៤ នៃសេចក្តីព្រាងច្បាប់

មាត្រា ១៤ អនុញ្ញាតឱ្យក្រសួងមហាផ្ទៃស្វែងរក និងរឹបអូសប្រព័ន្ធកុំព្យូទ័រ និងទិន្នន័យកុំព្យូទ័រ នៅពេលមានដីកាពីព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ។ គួរឱ្យកត់សម្គាល់ ស្របតាមមាត្រា ១៣(៣) នៃសេចក្តីព្រាងច្បាប់ ក្រសួងមហាផ្ទៃ ក៏មានសិទ្ធិអំណាចក្នុងការ «បិទមិនអាចប្រើបាន ឬលុបចោលទិន្នន័យកុំព្យូទ័រនៅលើប្រព័ន្ធកុំព្យូទ័រដែលបានចូលមើលរួចនោះ»[43] នៅពេលកំពុងស្វែងរក ឬរឹបអូសប្រព័ន្ធកុំព្យូទ័រ និងទិន្នន័យកុំព្យូទ័រ។

មាត្រា ១៤ នៃសេចក្តីព្រាងច្បាប់ ក៏មិនបានកំណត់ពីរយៈពេលកំណត់នៃការស្វែងរក និងការរឹបអូសទិន្នន័យកុំព្យូទ័រនោះទេ។ មាត្រា ១៤ នៃសេចក្តីព្រាងច្បាប់ អនុញ្ញាតឱ្យក្រសួងមហាផ្ទៃលុបចោល ឬបិទមិនឱ្យប្រើបាននូវទិន្នន័យណាមួយនៅលើប្រព័ន្ធកុំព្យូទ័រ។ ខណៈដែលទំនងជាអាចអនុញ្ញាតបានក្រោមច្បាប់អន្តរជាតិ ក្នុងការអនុញ្ញាតឱ្យអាជ្ញាធរបិទមិនឱ្យប្រើនូវទិន្នន័យដែលជាផ្នែកមួយនៃការស៊ើបអង្កេតបទល្មើស[44] ការផ្តល់នូវអំណាចដោយសេរីក្នុងការលុបចោលទិន្នន័យកុំព្យូទ័រដោយគ្មានការត្រួតពិនិត្យ ទំនងជាការរំលោភបំពានសិទ្ធិឯកជនភាព។ ក្រោមមាត្រា ១៤ នៃសេចក្តីព្រាងច្បាប់ ក្រសួងមហាផ្ទៃ អាចលុបចោលទិន្នន័យដោយអចិន្ត្រៃយ៍បាន ប្រសិនបើក្រសួងចង់។ គ្មានលក្ខណៈវិនិច្ឆ័យណាមួយជាសេចក្តីយោងសម្រាប់ការកំណត់បែបនោះទេ ឬគ្មាន

---

[43] មាត្រា ១៤ នៃសេចក្តីព្រាងច្បាប់៖ ការស្វែងរក និងការរឹបអូសប្រព័ន្ធកុំព្យូទ័រ "ដើម្បីស្វែងរក ឬប្រមូលភស្តុតាងចាំបាច់សម្រាប់ស៊ើបអង្កេតបទល្មើសណាមួយនៅលើប្រព័ន្ធកុំព្យូទ័រ ឬមធ្យោបាយរក្សាទុកទិន្នន័យកុំព្យូទ័រដែលអាចផ្ទុកភស្តុតាងបទល្មើសនោះ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវស្នើសុំដីកាពីព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ ដើម្បី៖ - ស្វែងរក ឬភ្ជាប់ទៅកាន់ប្រព័ន្ធកុំព្យូទ័រ ឬផ្នែកណាមួយ និទិន្នន័យកុំព្យូទ័រដែលមានផ្ទុកនៅក្នុងប្រព័ន្ធនោះ និង - ស្វែងរក ឬភ្ជាប់ទៅកាន់មធ្យោបាយរក្សាទុកទិន្នន័យ ដែលមានផ្ទុកទិន្នន័យកុំព្យូទ័រនោះ -ដោយមានជំនួយតាមការចាំបាច់ និងប្រើសមត្ថភាពបច្ចេកទេសដែលមានស្រាប់។ ២. ប្រសិនបើក្នុងពេលស៊ើបអង្កេតដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើ មន្ត្រីនគរបាលយុត្តិធម៌មានហេតុផលសមរម្យជឿជាក់ថា ទិន្នន័យដែលកំពុងស្វែងរកនោះ មានរក្សាទុកនៅក្នុងប្រព័ន្ធកុំព្យូទ័រផ្សេង ឬផ្នែកណាមួយ ហើយទិន្នន័យនោះមានភ្ជាប់ទៅក្នុងប្រព័ន្ធកុំព្យូទ័រដំបូង មន្ត្រីនគរបាលយុត្តិធម៌ត្រូវស្នើសុំដីកាពីព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ ដើម្បីស្វែងរកប្រព័ន្ធផ្សេង មុននឹងបន្តស្វែងរក ឬភ្ជាប់ទៅកាន់ប្រព័ន្ធផ្សេងនោះ។ ៣. នៅក្នុងពេលស៊ើបអង្កេត ដូចមានចែងក្នុងកថាខណ្ឌទី ១ និងទី ២ ខាងលើ មន្ត្រីនគរបាលយុត្តិធម៌មានសិទ្ធិក្នុងការ៖ - រឹបអូស ឬរក្សាប្រព័ន្ធកុំព្យូទ័រ ឬផ្នែកណាមួយ ឬមធ្យោបាយរក្សាទុកទិន្នន័យកុំព្យូទ័រ ដែលមានកំណត់នៅក្នុងដីការបស់ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ; - ធ្វើ ឬរក្សាទុកច្បាប់ចម្លងនៃទិន្នន័យកុំព្យូទ័រទាំងនោះ; - រក្សាចំនួនទិន្នន័យកុំព្យូទ័រពាក់ព័ន្ធដែលបានផ្ទុកទុក; - បិទមិនឱ្យប្រើបាន ឬលុបចោលទិន្នន័យកុំព្យូទ័រនោះនៅក្នុងប្រព័ន្ធកុំព្យូទ័រដែលបានភ្ជាប់ចូលរួច។ ៤. ក្នុងករណីមាការរឹបអូសឧបករណ៍ ឬបរិក្ខារ អាចប៉ះពាល់យ៉ាងខ្លាំងដល់សមត្ថភាពប្រតិបត្តិការរបស់ម្ចាស់ឧបករណ៍ មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើ និងរក្សាទុកច្បាប់ចម្លងទិន្នន័យកុំព្យូទ័រដោយមិនចាំបាច់រឹបអូសឧបករណ៍ ឬបរិក្ខារនោះបាន។"

[44] *ជាឧទាហរណ៍ សូមមើល* មាត្រា ១៩(៣)(ឃ) នៃអនុសញ្ញាទីក្រុងប៊ុយដាប៉េស "បិទមិនឱ្យចូលប្រើបាន ឬលុបចោលទិន្នន័យកុំព្យូទ័រទាំងនោះនៅក្នុងប្រព័ន្ធកុំព្យូទ័រដែលបានភ្ជាប់ចូលរួច។"

លក្ខខណ្ឌតម្រូវណាមួយដែលថាម្ចាស់ទិន្នន័យពិតជាបានប្រព្រឹត្តបទល្មើសមែនឬអត់។ ដើម្បីអនុលោមតាមច្បាប់អន្តរជាតិ អភិក្រមប្រសើរជាងនេះ គឺតម្រូវឱ្យសេចក្តីព្រាងច្បាប់ផ្តល់ជាមធ្យោបាយមួយសម្រាប់ប្រគល់ត្រលប់នូវទិន្នន័យទាំងនោះ ឬបើកឱ្យអាចចូលប្រើវិញបានបន្ទាប់ពីបញ្ចប់នីតិវិធីតាមផ្លូវតុលាការ។

**អនុសាសន៍៖** មាត្រា ១៤ នៃសេចក្តីព្រាងច្បាប់ គួរត្រូវបានកែសម្រួល ដោយរួមបញ្ចូលនូវវិធានការការពារគ្រប់គ្រាន់ពាក់ព័ន្ធនឹងវិសាលភាពទិន្នន័យដែលត្រូវរក្សាទុក ស្វែងរក ឬរឹបអូស ជាឧទាហរណ៍ ទិន្នន័យមានពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។ មាត្រា ១៤ នៃសេចក្តីព្រាងច្បាប់ ក៏គួរត្រូវកែប្រែផងដែរ៖ (ក) កំណត់រយៈពេលនៃការស្វែងរក ឬរឹបអូសទិន្នន័យកុំព្យូទ័រ (ខ) កម្រិតថានៅពេលណាដែលទិន្នន័យកុំព្យូទ័រអាចត្រូវបានលុបចោល ឬបិទមិនអាចភ្ជាប់បាន ដោយក្រសួងមហាផ្ទៃ និង (គ) បញ្ជាក់ឱ្យបានច្បាស់ថា នៅពេលណាដែលទិន្នន័យទាំងនោះត្រូវប្រគល់ត្រលប់ទៅឱ្យម្ចាស់ទិន្នន័យវិញ។

## មាត្រា ១៥ នៃសេចក្តីព្រាងច្បាប់

មាត្រា ១៥ នៃសេចក្តីព្រាងច្បាប់ អនុញ្ញាតឱ្យក្រសួងមហាផ្ទៃ ប្រមូលទិន្នន័យចរាចរណ៍សម្រាប់រយៈពេលដំបូងចំនួន ១៤ ថ្ងៃនៅពេលដែលមានដីកាពីព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ។ ទោះជាយ៉ាងណាក្តី ក្រោមមាត្រា ១៥(២) នៃសេចក្តីព្រាងច្បាប់ ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ អាចពន្យារពេលបន្ថែម "សម្រាប់រយៈពេលមួយជាកំណត់"។[45] មាត្រានេះអនុញ្ញាតឱ្យមានការប្រមូល

[45] មាត្រា ១៥ នៃសេចក្តីព្រាងច្បាប់៖ ការប្រមូលទិន្នន័យចរាចរណ៍នៅក្នុងរយៈពេលមួយកំណត់ "១. បន្ទាប់ពីទទួលបានពាក្យសុំជាលាយលក្ខណ៍អក្សរពីមន្ត្រីនគរបាលយុត្តិធម៌ ចង្អុលបង្ហាញថាមានហេតុផលសមស្របគួរឱ្យជឿជាក់ថាទិន្នន័យចរាចរណ៍មានពាក់ព័ន្ធនឹងទំនាក់ទំនងជាក់លាក់ និងពាក់ព័ន្ធជាមួយនឹងបុគ្គលដែលស្ថិតក្រោមការស៊ើបអង្កេត តម្រូវសម្រាប់ការស៊ើបអង្កេតបទល្មើស ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ អាចចេញដីកាឱ្យអ្នកផ្តល់សេវា ប្រមូល ឬថតទុកទិន្នន័យចរាចរណ៍តាមពេលជាក់ស្តែង (real time) តាមមធ្យោបាយបច្ចេកទេស និងផ្តល់តែទិន្នន័យចរាចរណ៍ជាក់លាក់ប៉ុណ្ណោះទៅឱ្យមន្ត្រីនគរបាលយុត្តិធម៌។ ការប្រមូល ឬការថតទុកទិន្នន័យចរាចរណ៍តាមពេលជាក់ស្តែងទាំងនោះ មិនត្រូវបានបញ្ជាឱ្យធ្វើសម្រាប់រយៈពេលមួយដែលលើសពីអ្វីដែលចាំបាច់បំផុត និងក្នុងករណីណាក៏ដោយ មិនត្រូវលើរយៈពេល ១៤ ថ្ងៃ។ ២. នៅពេលទទួលបានពាក្យសុំជាលាយលក្ខណ៍អក្សរស្តីពីការពន្យារពេលពីមន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ អាចអនុញ្ញាតតាមការស្នើសុំនោះសម្រាប់រយៈពេលមួយកំណត់បន្ថែម។ ៣. មាត្រានេះ អនុវត្តចំពោះតែការស៊ើបអង្កេតពាក់ព័ន្ធនឹងបទល្មើសធ្ងន់ធ្ងរប៉ុណ្ណោះ។ ៤. ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ ក៏អាចតម្រូវឱ្យអ្នកផ្តល់សេវារក្សាការសម្ងាត់ចំពោះដីកាដែលតម្រូវឱ្យប្រមូលទិន្នន័យចរាចរណ៍តាមពេលជាក់ស្តែងផងដែរ។»

ទិន្នន័យដោយគ្មានកំណត់។ ការប្រមូលទិន្នន័យនេះគឺសម្រាប់តែនៅពេលណាដែលក្រសួងមហាផ្ទៃត្រូវការស៊ើបអង្កេត "បទល្មើសធ្ងន់ធ្ងរ" ប៉ុណ្ណោះ។[46]

**អនុសាសន៍៖** មាត្រា ១៥ នៃសេចក្តីព្រាងច្បាប់ គួរត្រូវបានកែសម្រួល ដោយតម្រូវឱ្យមានការត្រួតពិនិត្យតាមផ្លូវតុលាការ មុននឹងប្រមូលទិន្នន័យ ដូចជាតម្រូវឱ្យមានការចាប់ផ្តើមតាមផ្លូវតុលាការកម្រិតខ្ពស់ជាងនេះ។ មាត្រា ១៥ នៃសេចក្តីព្រាងច្បាប់ គួររួមបញ្ចូលរយៈពេលកំណត់មួយសម្រាប់ការប្រមូលទិន្នន័យ។ មាត្រា ១៥ នៃសេចក្តីព្រាងច្បាប់ គួរកំណត់ពីបទល្មើសព្រហ្មទណ្ឌណាដែលអនុញ្ញាតឱ្យក្រសួងមហាផ្ទៃធ្វើការប្រមូលទិន្នន័យតាមពេលជាក់ស្តែងបាន និងកំណត់ថាទិន្នន័យបែបណាដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការប្រព្រឹត្តសកម្មភាពឧក្រិដ្ឋដែលបានលើកឡើង។ ជាចុងក្រោយ មាត្រា ១៥ នៃសេចក្តីព្រាងច្បាប់ គួរត្រូវបានកែសម្រួល ដោយរួមបញ្ចូលវិធានការការពារពាក់ព័ន្ធនឹងការប្រើប្រាស់ ការរក្សាទុក និងការលុបចោល/ការកំទេចចោលទិន្នន័យដែលប្រមូលបាន។

## មាត្រា ១៦ នៃសេចក្តីព្រាងច្បាប់

មាត្រា ១៦ នៃសេចក្តីព្រាងច្បាប់ ផ្តល់សិទ្ធិអំណាចដល់ក្រសួងមហាផ្ទៃក្នុងការស្ទាក់ចាប់ "ខ្លឹមសារទិន្នន័យ" នៅពេលមានដីកាពីព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ បានរហូតដល់ទៅរយៈពេល ១៤ ថ្ងៃ។ ក៏ប៉ុន្តែ តាមមាត្រា ១៦(២) នៃសេចក្តីព្រាងច្បាប់ ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ អាចពន្យារពេលបន្ថែម "សម្រាប់រយៈពេលមួយជាកំណត់"[47] ដែលអនុញ្ញាតឱ្យបន្តការស្ទាក់ចាប់

---

[46] វាក្យស័ព្ទ «បទល្មើសធ្ងន់ធ្ងរ» មិនត្រូវបានឱ្យនិយមន័យនោះទេ។

[47] មាត្រា ១៦ នៃសេចក្តីព្រាងច្បាប់៖ ការស្ទាក់ចាប់ខ្លឹមសារទិន្នន័យ "១. បន្ទាប់ពីទទួលបានពាក្យសុំជាលាយលក្ខណ៍អក្សរពីមន្ត្រីនគរបាលយុត្តិធម៌ ចង្អុលបង្ហាញថាមានហេតុផលសមស្របគួរឱ្យជឿជាក់ថាទិន្នន័យខ្លឹមសារមានពាក់ព័ន្ធនឹងបុគ្គលដែលស្ថិតក្រោមការស៊ើបអង្កេត តម្រូវសម្រាប់ការស៊ើបអង្កេតបទល្មើស ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ អាចចេញដីកា៖ ក. ឱ្យមន្ត្រីនគរបាលយុត្តិធម៌ប្រមូល ឬថតទុកទំនាក់ទំនងជាក់លាក់ ដោយប្រើមធ្យោបាយបច្ចេកទេសក្នុងប្រព័ន្ធកុំព្យូទ័រ តាមពេលជាក់ស្តែង (real time); ខ. ឱ្យអ្នកផ្តល់សេវា ប្រមូល ថតទុក ឬសហការ និងផ្តល់ជំនួយដល់មន្ត្រីនគរបាលយុត្តិធម៌ក្នុងការប្រមូល ឬថតទុកទិន្នន័យខ្លឹមសារនៃទំនាក់ទំនងជាក់លាក់ដែលបញ្ជូនតាមប្រព័ន្ធកុំព្យូទ័រ ក្នុងពេលវេលាជាក់ស្តែង (real time) តាមរយៈសមត្ថភាពបច្ចេកទេសដែលមានស្រាប់។ ការប្រមូលតាមពេលជាក់ស្តែង (real time) ឬការថតទុកទិន្នន័យខ្លឹមសារតាមពេលជាក់ស្តែងទាំងនោះ មិនត្រូវបានបញ្ជាឱ្យធ្វើសម្រាប់រយៈពេលមួយដែលលើសពីអ្វីដែលចាំបាច់បំផុត និង ក្នុងករណីណាក៏ដោយ មិនត្រូវលើរយៈពេល ១៤ ថ្ងៃ។ ២. នៅពេលទទួលបានពាក្យសុំជាលាយលក្ខណ៍អក្សរស្តីពីការពន្យារពេលពី មន្ត្រីនគរបាលយុត្តិធម៌ ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ អាចអនុញ្ញាតតាមការស្នើសុំនោះសម្រាប់រយៈពេលមួយកំណត់បន្ថែម។ ៣. មាត្រានេះ អនុវត្តចំពោះតែការស៊ើបអង្កេតពាក់ព័ន្ធនឹងបទល្មើសធ្ងន់ធ្ងរ ឬបទល្មើសពាក់ព័ន្ធនឹងសន្តិសុខជាតិតែប៉ុណ្ណោះ។ ៤. ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ ក៏អាចតម្រូវឱ្យអ្នកផ្តល់សេវារក្សាការសម្ងាត់ចំពោះដីកាដែលតម្រូវឱ្យស្ទាក់ចាប់ទិន្នន័យខ្លឹមសារផងដែរ។»

ទិន្នន័យនោះដោយគ្មានកំណត់។ លើសពីនេះទៀត ការស្ទាក់ចាប់នេះ អាចធ្វើទៅបានក្នុងករណីដែលក្រសួងមហាផ្ទៃកំពុងស៊ើបអង្កេត «បទល្មើសធ្ងន់ធ្ងរ ឬបទល្មើសពាក់ព័ន្ធនឹងសន្តិសុខជាតិ» តែប៉ុណ្ណោះ។[48]

**អនុសាសន៍៖** មាត្រា ១៦ នៃសេចក្តីព្រាងច្បាប់ គួរត្រូវបានកែសម្រួល ដោយតម្រូវឱ្យមានការត្រួតពិនិត្យតាមផ្លូវតុលាការ មុននឹងប្រមូលទិន្នន័យ ដូចជាតម្រូវឱ្យមានការចាប់ផ្តើមតាមផ្លូវតុលាការកម្រិតខ្ពស់ជាងនេះ។ មាត្រា ១៦ នៃសេចក្តីព្រាងច្បាប់ គួររួមបញ្ចូលរយៈពេលកំណត់មួយសម្រាប់ការប្រមូលទិន្នន័យ និងគួរកំណត់ពីបទល្មើសព្រហ្មទណ្ឌណា ដែលអនុញ្ញាតឱ្យក្រសួងមហាផ្ទៃធ្វើការស្ទាក់ចាប់ទិន្នន័យ និងកំណត់ថាទិន្នន័យបែបណាដែលពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការប្រព្រឹត្តសកម្មភាពឧក្រិដ្ឋដែលបានលើកឡើង។ ជាចុងក្រោយ មាត្រា ១៦ នៃសេចក្តីព្រាងច្បាប់ គួរត្រូវបានកែសម្រួល ដោយរួមបញ្ចូលវិធានការការពារពាក់ព័ន្ធនឹងការប្រើប្រាស់ ការរក្សាទុក និងការលុបចោល/ការកំទេចចោលទិន្នន័យដែលប្រមូលបាន។

## កាតព្វកិច្ចមិនសមហេតុផលសម្រាប់អ្នកផ្តល់សេវា

**បញ្ហា៖** មាត្រា ៨ និង ៩ នៃសេចក្តីព្រាងច្បាប់ បានដាក់កាតព្វកិច្ចមិនសមហេតុផលទៅឱ្យអ្នកផ្តល់សេវា ដែលទំនងជាធ្វើឱ្យទន់ខ្សោយដល់សិទ្ធិឯកជនភាព។

**ការពិភាក្សា៖** មាត្រា ៨ នៃសេចក្តីព្រាងច្បាប់ តម្រូវឱ្យអ្នកផ្តល់សេវា ៖ (ក) «រក្សា និងគ្រប់គ្រងឱ្យបានត្រឹមត្រូវ» នូវការចុះឈ្មោះ និងបែបបទស្នើសុំ របស់អ្នកប្រើប្រាស់ និង (ខ) ឃាត់ទុករាល់ «ទិន្នន័យចរាចរណ៍» ទាំងអស់សម្រាប់រយៈពេលយ៉ាងតិច ១៨០ ថ្ងៃ និង ត្រូវមាន «ជំនាញបច្ចេកទេសគ្រប់គ្រាន់» ដើម្បីផ្តល់ «ព័ត៌មានរបស់អ្នកប្រើប្រាស់សេវា» ទៅឱ្យអាជ្ញាធរ។[49] ការមិន

---

[48] វាក្យស័ព្ទ «បទល្មើសធ្ងន់ធ្ងរ» និង «បទល្មើសពាក់ព័ន្ធនឹងសន្តិសុខជាតិ» មិនត្រូវបានឱ្យនិយមន័យនោះទេ។

[49] មាត្រា ៨ នៃសេចក្តីព្រាងច្បាប់៖ ការគ្រប់គ្រងការចុះឈ្មោះ និងការស្នើសុំរបស់អ្នកប្រើប្រាស់សេវា "អ្នកផ្តល់សេវា ត្រូវ ៖ ១. មានកាតព្វកិច្ចរក្សា និងគ្រប់គ្រងឱ្យបានត្រឹមត្រូវនូវការចុះឈ្មោះ និងការស្នើសុំរបស់អ្នកប្រើប្រាស់សេវា; ២. រក្សាទុកទិន្នន័យចរាចរណ៍សម្រាប់រយៈពេល ១៨០ ថ្ងៃ; ៣. មានជំនាញបច្ចេកទេសគ្រប់គ្រាន់ក្នុងការស្វែងរក និផ្តល់ព័ត៌មានរបស់អ្នកប្រើប្រាស់សេវា នៅពេលមានការស្នើសុំពីអាជ្ញាធរដែលទទួលបានការអនុញ្ញាតតាមច្បាប់។"

ឃាត់ទុករាល់ទិន្នន័យចរាចរណ៍ទាំងអស់ក្នុងរយៈពេល ១៨០ ថ្ងៃ អ្នកផ្តល់សេវា ត្រូវពិន័យជាប្រាក់ចន្លោះពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល។[50]

នៅក្នុងមាត្រា ៨ នៃសេចក្តីព្រាងច្បាប់ មានបញ្ហាចំបងៗចំនួនពីរ។ បញ្ហាទី ១ ដោយផ្អែកលើការបកស្រាយមាត្រានេះ វាអាចជាការជ្រៀតជ្រែកតាមអំពើចិត្តទៅលើសិទ្ធិឯកជនភាពដែលការពារដោយកតិកាសញ្ញា ICCPR។[51] ឃ្លាថា «ការរក្សា និងគ្រប់គ្រងឱ្យបានត្រឹមត្រូវនូវការចុះឈ្មោះ និងការស្នើសុំ» របស់អ្នកប្រើប្រាស់ មិនច្បាស់ថាមានន័យយ៉ាងណា។[52] ប្រសិនបើអ្នកផ្តល់សេវា តម្រូវឱ្យប្រមូល និងរក្សាទុករាល់ព័ត៌មានអត្តសញ្ញាណបុគ្គលគ្រប់ប្រភេទទាំងអស់ រួមទាំងឈ្មោះពិតរបស់បុគ្គល លេខអត្តសញ្ញាណប័ណ្ណ ថ្ងៃខែឆ្នាំកំណើត ជាដើម នោះទំនងជាកើតមានការរំលោភបំពានដល់សិទ្ធិឯកជនភាពដែលការពារដោយកតិកាសញ្ញា ICCPR។

អនាមិកភាព ត្រូវបានទទួលស្គាល់ថាជាធាតុផ្សំសំខាន់នៃការការពារការបញ្ចេញមតិដោយសេរី ឯកជនភាព គណនេយ្យភាពនយោបាយ និងការចូលរួមជាសាធារណៈ។[53] មនុស្សគ្រប់រូបមានសិទ្ធិប្រាស្រ័យទាក់ទងគ្នាដោយអនាមិក ឬប្រើរហស្សនាមនៅលើប្រព័ន្ធអ៊ិនធើណិត និងដើម្បីធានាការរក្សាការសម្ងាត់នៃទំនាក់ទំនង និងព័ត៌មានបុគ្គល មិនឱ្យតតិយជនចូលទៅមើលបាន

---

[50] មាត្រា ២៥ នៃសេចក្តីព្រាងច្បាប់៖ ការធ្វេសប្រហែសក្នុងការគ្រប់គ្រងការចុះឈ្មោះ និងការស្នើសុំរបស់អ្នកប្រើប្រាស់សេវា «អ្នកផ្តល់សេវាណាដែលធ្វេសប្រហែសមិនអាចគ្រប់គ្រងការចុះឈ្មោះ ការស្នើសុំ ឬទិន្នន័យរបស់អ្នកប្រើប្រាស់សេវា ដូចមានចែងក្នុងមាត្រា ៨ នៃច្បាប់នេះ ត្រូវពិន័យជាប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀល ទៅ ១០ ០០០ ០០០ (ដប់លាន) រៀល។»

[51] មាត្រា ១៧ នៃកតិកាសញ្ញា ICCPR «១. គ្មានជនណាម្នាក់ ត្រូវទទួលរងការជ្រៀតជ្រែកតាមអំពើចិត្ត ឬដោយខុសច្បាប់ ក្នុងជីវិតឯកជន គ្រួសារ លំនៅដ្ឋាន សំបុត្រឆ្លើយឆ្លងរបស់ខ្លួន ឬត្រូវរងការប៉ះពាល់ ដោយខុសច្បាប់ទៅលើកិត្តិយស និងកេរ្តិ៍ឈ្មោះរបស់ខ្លួនឡើយ។ ២. ជនគ្រប់រូបមាន សិទ្ធិឱ្យច្បាប់ការពារប្រឆាំងនឹងការជ្រៀតជ្រែក ឬការប៉ះពាល់បែបនេះ។»

[52] មាត្រា ២(១២) នៃសេចក្តីព្រាងច្បាប់ កំណត់និយមន័យ «ព័ត៌មានអ្នកប្រើប្រាស់សេវា» ថាជា «ព័ត៌មានទាំងឡាយដែលស្ថិតក្នុងទម្រង់ ដែលបង្កើតជាអត្តសញ្ញាណរបស់អ្នកប្រើប្រាស់សេវា ដូចជាឈ្មោះ អាសយដ្ឋាន កំណត់ត្រាពេលវេលាប្រើប្រាស់ និងរយៈពេលប្រើប្រាស់ រយៈពេលប្រើសេវា (រួមទាំងកាលបរិច្ឆេទចាប់ផ្តើមប្រើសេវា) និងប្រភេទសេវាដែលកំពុងប្រើប្រាស់ លេខទូរស័ព្ទ ឬលេខឧបករណ៍ លេខ ឬអត្តសញ្ញាណរបស់អ្នកប្រើប្រាស់ផ្សេង រួមទាំងអាសយដ្ឋានបណ្តាញអ៊ិនធើណេតដែលដាក់ឱ្យប្រើប្រាស់បណ្តោះអាសន្ន (រួមទាំងអាសយដ្ឋានពិធីសារនៅលើប្រព័ន្ធអ៊ិនធើណិត) មធ្យោបាយ និងប្រភពបង់ប្រាក់សេវា (រួមទាំងប័ណ្ណឥណទាន ឬលេខគណនីធនាគារ)។» ក៏ប៉ុន្តែ នៅក្នុងសេចក្តីព្រាងច្បាប់នេះ មិនកំណត់ឱ្យបានច្បាស់ថា អ្នកផ្តល់សេវា តម្រូវឱ្យយករាល់ព័ត៌មានទាំងអស់ដែលមានកំណត់នៅក្នុងនិយមន័យ «ព័ត៌មានអ្នកប្រើប្រាស់សេវា» ឬយ៉ាងណា។

[53] កថាខណ្ឌទី ៤៧ នៃ «របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ ដោយ David Kaye» ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៥ ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/HRC/29/32។

តាមរយៈជំនួយបច្ចេកវិទ្យាឌីជីថល។ ដើម្បីជានាអនុលោមភាពនៃកតិកាសញ្ញា ICCPR រដ្ឋសមាជិកមានកាតព្វកិច្ចបង្ហាញថាការជ្រៀតជ្រែកទៅលើសិទ្ធិឯកជនភាព មិនត្រូវធ្វើឡើងតាមអំពើចិត្ត ឬខុសច្បាប់នោះទេ។ ការតម្រូវឱ្យអ្នកផ្តល់សេវាទាំងអស់រក្សាទុកព័ត៌មានបុគ្គលដោយគ្មានកំណត់របស់អ្នកប្រើប្រាស់ បង្កើតជាការជ្រៀតជ្រែកតាមអំពើចិត្តទៅលើសិទ្ធិឯកជនភាព។ អ្នករាយការណ៍ពិសេស បានកត់សម្គាល់ដោយឡែកថា នីតិកម្មប្រហាក់ប្រហែលនៅក្នុងប្រទេសអ៊ីរ៉ង់ និងរុស្ស៊ី ដែលតម្រូវឱ្យអ្នកប្រើប្រាស់អ៊ិនធើណិតនៅតាមហាងអ៊ិនធើណិត ចុះឈ្មោះពិតរបស់ខ្លួន បង្កើតបានជាការហាមឃាត់អនាមិកភាពនៅលើប្រព័ន្ធអ៊ិនធើណិត ហើយជាលទ្ធផល គឺជាការជ្រៀតជ្រែកដែលមិនអាចទទួលយកបានទៅលើសេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិឯកជនភាពរបស់បុគ្គល។[54]

បញ្ហាទី ២ គឺការតម្រូវឱ្យឃាត់ទុកទិន្នន័យរបស់អ្នកប្រើប្រាស់ទាំងអស់សម្រាប់រយៈពេល ១៨០ ថ្ងៃ បង្កើតជាការប្រមូលផ្តុំក្នុងចំនួនដ៏ច្រើននូវទិន្នន័យទំនាក់ទំនងឯកជន ដែលអាចមានផលប៉ះពាល់ធ្ងន់ធ្ងរ និងអវិជ្ជមានដល់សេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិឯកជនភាព។ ការឃាត់ទុកទិន្នន័យក្នុងចំនួនដ៏ច្រើនដែលខានមិនបាននេះ បង្កើនវិសាលភាពនៃការតាមដានរបស់រដ្ឋ បង្កើនចំណាយអាជីវកម្ម និងទទួលបានចំណូលតិចជាងមុន និងបង្កើនលទ្ធភាពដែលថាទិន្នន័យអាចត្រូវបានលួចយកបាត់ ត្រូវបានបង្ហាញដោយដឹងដោយចៃដន្យ ឬប្រើប្រាស់សម្រាប់បន្លំបោកប្រាស់។[55] "រដ្ឋត្រូវតែបញ្ឈប់បង្ខិតបង្ខំឱ្យវិស័យឯកជនអនុវត្តនូវវិធានការ ដែលធ្វើឱ្យប៉ះពាល់ដល់ឯកជនភាព សុវត្ថិភាព និងអនាមិកភាពនៃសេវាគមនាគមន៍ រួមទាំងការតម្រូវឱ្យកសាងសមត្ថភាពស្ទាក់ចាប់ ក្នុងគោលបំណងតាមដានរបស់រដ្ឋ ឬហាមឃាត់ការប្រើប្រាស់កូដនីយកម្ម។"[56]

**អនុសាសន៍៖** ដើម្បីអនុលោមតាមបទដ្ឋានសិទ្ធិមនុស្សអន្តរជាតិ

---

[54] កថាខណ្ឌទី ៤៩-៥០ នៃ «របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ ដោយ David Kaye» ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១៥ ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/HRC/29/32។

[55] កថាខណ្ឌទី ៦៧ នៃ «របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ ដោយ Frank La Rue» ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៣ ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/HRC/23/40។

[56] កថាខណ្ឌទី ៩៦ នៃ «របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ ដោយ Frank La Rue» ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៣ ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/HRC/23/40។

- កថាខណ្ឌទី ១ នៃមាត្រា ៨ គួរត្រូវបានកែសម្រួលដើម្បីកំណត់ឱ្យបានច្បាស់ពីប្រភេទព័ត៌មានដែលអ្នកផ្តល់សេវាត្រូវស្នើសុំពីអ្នកប្រើប្រាស់ នៅលើឯកសារស្នើសុំ និងចុះឈ្មោះសម្រាប់សេវាអ៊ិនធើណិត។ ព័ត៌មានតម្រូវឱ្យមាន ត្រូវតែស្ថិតក្នុងកម្រិតតិចតួច និងអនុញ្ញាតឱ្យប្រើប្រាស់អ៊ិនធើណិតជាលក្ខណៈអនាមិកបានផងដែរ។

- កថាខណ្ឌទី ២ នៃមាត្រា ៨ (“រក្សាទុកទិន្នន័យចរាចរណ៍សម្រាប់រយៈពេលយ៉ាងតិច ១៨០ ថ្ងៃ”) គួរត្រូវបានលុបចោល ដោយហេតុថាកថាខណ្ឌនេះបង្កើតបានជាលក្ខខណ្ឌសម្រាប់ប្រមូលទិន្នន័យក្នុងចំនួនដ៏ច្រើន និងការតាមដានក្នុងទ្រង់ទ្រាយធំ។ (មាត្រា ១៥ និង ១៦ នៃសេចក្តីព្រាងច្បាប់ ផ្តល់លទ្ធភាពដល់អាជ្ញាធរក្នុងការប្រមូល និងស្ទាក់ចាប់ទិន្នន័យកុំព្យូទ័រ ក្នុងអំឡុងពេលអនុវត្តច្បាប់ និងពេលស៊ើបអង្កេតតាមផ្លូវតុលាការ)។ ម្យ៉ាងវិញទៀត កថាខណ្ឌទី ២ នៃមាត្រា ៨ គួរត្រូវបានកែសម្រួល ដោយតម្រូវឱ្យអ្នកផ្តល់សេវាឃាត់ទុកទិន្នន័យចរាចរណ៍សម្រាប់រយៈពេលខ្លីមួយ ដូចជាតែ ១០ ថ្ងៃ។ ចំនួនថ្ងៃនេះ អាចឱ្យអាជ្ញាធរធ្វើការស៊ើបអង្កេតបទល្មើសកំពុងប្រព្រឹត្តបាន និងអាចអនុលោមតាមសិទ្ធិឯកជនភាពបានផងដែរ។

## បញ្ហាផ្សេងទៀត

- មាត្រា ២ នៃសេចក្តីព្រាងច្បាប់ បង្កើតជាយុត្តាធិការសកល។ វិសាលភាពសេចក្តីព្រាងច្បាប់នេះ មានចែងនៅក្នុងមាត្រា ២ ថា «អនុវត្តចំពោះបទល្មើសបច្ចេកវិទ្យាព័ត៌មានដែលប្រព្រឹត្តនៅក្នុង ឬនៅក្រៅព្រះរាជាណាចក្រកម្ពុជា ហើយដែលប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់ ឬផលប្រយោជន៍សាធារណៈនៃព្រះរាជាណាចក្រកម្ពុជា។»[57] កថាខណ្ឌនេះបង្កើតជាយុត្តាធិការសកលទៅលើអ្នកប្រើប្រាស់អ៊ិនធើណិតទាំងអស់ និងបង្កើតជាបញ្ហាចំបងៗចំនួនពីរ។ បញ្ហាទី ១ អ្នកប្រើប្រាស់អ៊ិនធើណិតជាច្រើន ជាពិសេសអ្នកនៅក្រៅព្រះរាជាណាចក្រកម្ពុជា មិនបានដឹងលឺពីសេចក្តីព្រាងច្បាប់ ឬការអនុវត្តច្បាប់នេះទេ។ បញ្ហាទី ២ ចំណាត់ប្រភេទនៃបទល្មើសដែលមានរៀបរាប់នៅក្នុងសេចក្តីព្រាងច្បាប់ដែល «ប៉ះពាល់ដល់សន្តិសុខ សណ្តាប់ធ្នាប់ ឬផលប្រយោជន៍សាធារណៈនៃព្រះរាជា

[57] មាត្រា ២ នៃសេចក្តីព្រាងច្បាប់

ណាចក្រកម្ពុជា» មានលក្ខណៈទូលាយ ដែលស្ទើរតែការពិភាក្សាពីកម្ពុជាទាំងអស់ ជាមតិអវិជ្ជមាន ឬជាការរិះគន់ណាមួយ អាចត្រូវបានចាត់ថ្នាក់ ថាជាបទល្មើសមួយដែរ។

- មាត្រា ៣០ នៃសេចក្តីព្រាងច្បាប់ ហាមឃាត់ «ការផ្សព្វផ្សាយ និងការប្រមូលមូលនិធិ ដើម្បីទិញ លក់ ផ្លាស់ប្តូរ ឬប្រតិបត្តិការទូទាត់រូបិយវត្ថុ Crypto (Cryptocurrency) តាមរយៈបច្ចេកវិទ្យាព័ត៌មាន ដោយគ្មានការអនុញ្ញាត ឬអាជ្ញាប័ណ្ណពីអាជ្ញាធរមានសមត្ថកិច្ច...»[58] រូបិយវត្ថុ Crypto គឺជាវិធីទូទាត់ប្រាក់ដែលគេទទួលស្គាល់ច្រើន និងប្រើប្រាស់នៅក្នុងធុរកិច្ច រដ្ឋាភិបាល អង្គការសង្គមស៊ីវិល និងរវាងបុគ្គល។ ក្រៅពីទោសព្រហ្មទណ្ឌសម្រាប់ការទូទាត់តាមរូបិយវត្ថុ Crypto រាជរដ្ឋាភិបាលកម្ពុជា គួរបង្កើតជាក្របខណ្ឌការងារគតិយុត្តិ ដែលអនុញ្ញាតឱ្យធ្វើការទូទាត់ប្រាក់ក្នុងលក្ខខណ្ឌច្បាស់លាស់ និងមានតម្លាភាព។
- មាត្រា ៣២ នៃសេចក្តីព្រាងច្បាប់ ហាមឃាត់ការលួចភ្ជាប់ទៅកាន់កុំព្យូទ័រ ហើយការប្រព្រឹត្តនេះគឺជាបទល្មើសព្រហ្មទណ្ឌ។[59] ទោសព្រហ្មទណ្ឌ នឹងកើនឡើង ប្រសិនបើកើតមាន "ករណីលួចភ្ជាប់" ធ្វើឡើងដោយ «មានចេតនាទាញយក ថតចម្លង ប្រើប្រាស់ និង/ឬ បញ្ជូនទិន្នន័យកុំព្យូទ័រ (មាត្រា ៣២(២) នៃសេចក្តីព្រាងច្បាប់) ដោយរំលោភបំពានលើវិធានការសន្តិសុខ (មាត្រា ៣២(៣) នៃសេចក្តីព្រាងច្បាប់) ឬនៅលើប្រព័ន្ធកុំព្យូទ័រ

---

[58] មាត្រា ៣០ នៃសេចក្តីព្រាងច្បាប់៖ រូបិយវត្ថុ Crypto "ការផ្សព្វផ្សាយ និងការប្រមូលមូលនិធិ ដើម្បីទិញ លក់ ផ្លាស់ប្តូរ ឬប្រតិបត្តិការទូទាត់រូបិយវត្ថុ Crypto (Cryptocurrency) តាមរយៈបច្ចេកវិទ្យាព័ត៌មាន ដោយគ្មានការអនុញ្ញាត ឬអាជ្ញាប័ណ្ណពីអាជ្ញាធរមានសមត្ថកិច្ច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ ខែទៅ ៥ ឆ្នាំ និងពិន័យជាប្រាក់ពី ១០ ០០០ ០០០ (ដប់លាន) រៀល ទៅ ៥០ ០០០ ០០០ (ហាសិបលាន) រៀល។"

[59] មាត្រា ៣២ នៃសេចក្តីព្រាងច្បាប់៖ "១. ជនណាដែលមានចេតនាលួចភ្ជាប់ទៅកាន់ប្រព័ន្ធកុំព្យូទ័រផ្នែកណាមួយ ឬទាំងស្រុង ដោយគ្មានមូលហេតុត្រឹមត្រូវ ឬហេតុផលស្របច្បាប់ ឬការអនុញ្ញាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែទៅ ១ (មួយ) ឆ្នាំ និងពិន័យជាប្រាក់ពី ១ ០០០ ០០០ (មួយលាន) រៀលទៅ ៦ ០០០ ០០០ (ប្រាំមួយលាន) រៀល។ ២. ជនណាដែលធ្វើសកម្មភាព ដូចមានចែងក្នុងកថាខណ្ឌទី១ ខាងលើ ក្នុងគោលបំណងទាញយក ថតចម្លង ប្រើប្រាស់ និង/ឬ បញ្ជូនទិន្នន័យកុំព្យូទ័រ ឬព័ត៌មានរបស់ម្ចាស់ទិន្នន័យ ដោយគ្មានការអនុញ្ញាត ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១ (មួយ) ខែទៅ ៣ (បី) ឆ្នាំ និងពិន័យប្រាក់ពី ២ ០០០ ០០០ (ពីរលាន) រៀលទៅ ១០ ០០០ ០០០ (ដប់លាន) រៀល។ ៣. ជនណាដែលធ្វើសកម្មភាពដែលមានចែងក្នុងកថាខណ្ឌទី១ និង/ឬ ទី២ ខាងលើ ដោយរំលោភបំពានលើវិធានការសន្តិសុខ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ (ប្រាំមួយ) ខែ ទៅ ៥ (ប្រាំ) ឆ្នាំ និងពិន័យប្រាក់ពី ៨ ០០០ ០០០ (ប្រាំបីលាន) រៀលដល់ ២៤ ០០០ ០០០ (ម្ភៃបួនលាន) រៀល។ ៤. ជនណាដែលធ្វើសកម្មភាពដែលមានចែងក្នុងកថាខណ្ឌទី១ និង/ឬ ទី២ ខាងលើ ដែលទាក់ទងនឹងប្រព័ន្ធកុំព្យូទ័រ ទិន្នន័យកុំព្យូទ័រ ឬវិធានការសន្តិសុខ ដែលចាត់ថ្នាក់ជាការសម្ងាត់ ឬស្ថិតក្រោមកិច្ចការពារពិសេស ឬទាក់ទងនឹងសន្តិសុខជាតិ ឬព័ត៌មានសម្ងាត់យោធា តាមរយៈការភ្ជាប់ដោយសម្ងាត់ ឬការបញ្ជូនដោយផ្ទាល់ ឬតាមទម្រង់អេឡិចត្រូម៉ាញេទិច ឬទម្រង់ផ្សេងដែលមិនអាចមើលឃើញនឹងភ្នែកបាន ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ២ (ពីរ) ឆ្នាំ ទៅ ១០ (ដប់) ឆ្នាំ និងពិន័យប្រាក់ពី ២៤ ០០០ ០០០ (ម្ភៃបួនលាន) រៀលដល់ ១០០ ០០០ ០០០ (មួយរយលាន) រៀល។"

ដែល «ចាត់ថ្នាក់ជាការសម្ងាត់ ឬស្ថិតក្រោមកិច្ចការពារយ៉ាងពិសេស ឬទាក់ទងនឹងសន្តិសុខជាតិ ឬព័ត៌មានសម្ងាត់យោធា តាមរយៈការភ្ជាប់ដោយសម្ងាត់ ឬការបញ្ជូនដោយផ្ទាល់ ឬតាមទម្រង់អេឡិចត្រូម៉ាញេទិច ឬទម្រង់ផ្សេងដែលមិនអាចមើលឃើញនឹងភ្នែកបាន...» (មាត្រា ៣២(៤) នៃសេចក្តីព្រាងច្បាប់)។

- មាត្រា ៣២ នៃសេចក្តីព្រាងច្បាប់ គឺជាការរឹតត្បិតសមហេតុផលសំដៅបង្ការការវាយប្រហារ (hack) ការបញ្ចូលមេរោគ ជាដើម និងសំដៅលើចេតនាប្រព្រឹត្តបទល្មើស។ ទោះជាយ៉ាងណាក្តី ទោសបន្ថែមចំពោះការប្រព្រឹត្តបទល្មើសដូចមានចែងក្នុងកថាខណ្ឌ ២, ៣ និង ៤ ហាក់ដូចជាសំដៅលើអ្នកសារព័ត៌មាន អ្នកផ្តល់ព័ត៌មាន និងអ្នកឃ្លាំមើលផ្សេងទៀត ដែលព្យាយាមបង្ហាញឱ្យដឹងពីការរំលោភបំពានសិទ្ធិមនុស្ស អំពើពុករលួយ ឬការបំពានផ្សេងទៀត។ អ្នកសារព័ត៌មាន និងអ្នកផ្តល់ព័ត៌មាន ជារឿយៗ ត្រូវការភ្ជាប់ទៅកាន់ប្រព័ន្ធកុំព្យូទ័រ ដោយមិនចាំបាច់មានការអនុញ្ញាត ឬប្រើប្រាស់កម្មវិធីទៅលើកុំព្យូទ័រដើម្បីទទួលបានឯកសារពាក់ព័ន្ធ ដោយមិនចាំបាច់មានការអនុញ្ញាត ហើយសកម្មភាពទាំងនេះ តែងតែធ្វើឡើងដើម្បីបំពេញការងាររបស់ខ្លួន។ ទោះបីជារដ្ឋ ត្រូវកាត់បន្ថយ និងកំណត់ជាបទឧក្រិដ្ឋដល់ការតាមដានខុសច្បាប់ ច្បាប់មិនត្រូវសំដៅអ្នកផ្តល់ព័ត៌មាន ឬបុគ្គលដទៃ ដែលព្យាយាមបង្ហាញឱ្យដឹងពីការរំលោភបំពាននឹងសិទ្ធិមនុស្ស ឬផ្តល់ការត្រួតពិនិត្យស្របច្បាប់ទៅលើសកម្មភាពរបស់រដ្ឋាភិបាលនោះទេ។ ករណីលើកលែង ត្រូវធ្វើឡើងសម្រាប់អ្នកផ្តល់ព័ត៌មាន។[60] ហេតុដូច្នេះ ជាអនុសាសន៍ មាត្រាទាំងនេះត្រូវកែសម្រួល ដោយលើកលែងសកម្មភាពទាំងនោះ ប្រសិនបើធ្វើឡើងដោយ "សុទ្ធចិត្ត" និងមិនបង្កអន្តរាយដល់ប្រព័ន្ធកុំព្យូទ័រ។[61]

60 កថាខណ្ឌទី ៨៤ នៃ «របាយការណ៍របស់អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់ ដោយ Frank La Rue» ចុះថ្ងៃទី១៧ ខែមេសា ឆ្នាំ២០១៣ ឯកសាររបស់ក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ លេខ A/HRC/23/40។

61 ជាឧទាហរណ៍ សូមមើល ទំព័រទី ៤ នៃសេចក្តីប្រកាសរួម ចុះថ្ងៃទី ៦ ខែធ្នូ ឆ្នាំ២០០៤ ធ្វើឡើងដោយអ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីការលើកស្ទួយ និងការការពារសិទ្ធិសេរីភាពក្នុងការបញ្ចេញមតិ និងយោបល់, អ្នកតំណាងសេរីភាពសារព័ត៌មាននៃអង្គការសន្តិសុខ និងកិច្ចសហប្រតិបត្តិការនៅអឺរ៉ុប (OSCE), អ្នករាយការណ៍ពិសេសស្តីពីសេរីភាពក្នុងការបញ្ចេញមតិ នៃអង្គការបណ្តាប្រទេសនៅទ្វីបអាមេរិក (OAS)

## សេចក្តីសន្និដ្ឋាន

សេចក្តីព្រាងច្បាប់នេះ ត្រូវបានកែសម្រួលបានល្អប្រសើរជាងកំណែលើកមុនៗ។ ក៏ប៉ុន្តែ សេចក្តីព្រាងច្បាប់នេះនៅតែមានចែងមាត្រាមួយចំនួនដែលទំនងជាអាចរឹតត្បិតសេរីភាពក្នុងការបញ្ចេញមតិ ឬរំលោភបំពាននឹងសិទ្ធិឯកជនភាព ដែលផ្ទុយនឹងច្បាប់អន្តរជាតិ និងការអនុវត្តល្អបំផុតដែរ។ បទប្បញ្ញត្តិជាច្រើននៅក្នុងសេចក្តីព្រាងច្បាប់នេះដែលបំពាននឹងច្បាប់អន្តរជាតិ អាចត្រូវបានដោះស្រាយយ៉ាងងាយ។ប្រសិនបើសេចក្តីព្រាងច្បាប់ត្រូវបានកែសម្រួលដោយរួមបញ្ចូលនូវអនុសាសន៍ដែលបានលើកឡើងខាងលើ វាមិនត្រឹមតែអនុលោមតាមច្បាប់អន្តរជាតិប៉ុណ្ណោះទេ សេចក្តីព្រាងច្បាប់នេះក៏ផ្តល់នូវក្របខណ្ឌការងារស្របច្បាប់រឹងមាំដល់រាជរដ្ឋាភិបាលកម្ពុជាក្នុងការបង្ការ ស៊ើបអង្កេត និងផ្តន្ទាទោសសកម្មភាពឧក្រិដ្ឋ នៅក្នុងវិស័យព័ត៌មានវិទ្យា និងការពារដល់សេរីភាពក្នុងការបញ្ចេញមតិ និងសិទ្ធិឯកជនភាពរបស់ប្រជាជនកម្ពុជាទាំងមូលផងដែរ។

*មជ្ឈមណ្ឌល ICNL នៅតែបន្តផ្តល់ជំនួយបច្ចេកទេស តាមការចាំបាច់។*
*ដាក់ជូននៅថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ ២០២២*